នៅចំពោះមុខអង្គបុរេជំនុំជម្រះ
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០៤/២/០៧-០៩-២០០៩-អវតក/កសចស(អបជ__) |
| ដាក់ទៅ | : | អង្គបុរេជំនុំជម្រះ |
| ថ្ងៃដាក់ | : | ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញាជាតិ |
| ភាសាដើម | : | ខ្មែរ |

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 14-Dec-2018, 11:31
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គបុរេជំនុំជម្រះ: សម្ងាត់/Confidential

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិទាក់ទងនឹងដីកាដំណោះស្រាយ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង០០៤/២

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញាជាតិ**
លោកស្រី ជា លាង

**ចម្លងជូន:**
**សហព្រះរាជអាជ្ញាអន្តរជាតិ**
លោក Nicholas KOUMJIAN

**សហមេធាវី អោ អាន:**
មុំ សុជ្ជ
Richard ROGERS
Göran SLUITER

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ទាំងអស់នៃសំណុំរឿង០០៤/២**

**អ្នកទទួលឯកសារ:**
**អង្គបុរេជំនុំជម្រះ**
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម BAIK Kang Jin
ចៅក្រម ហួត វុទ្ធី

# I. សេចក្តីផ្តើម

1. នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយចំនួនពីរ ដែលក្នុងនោះ សហចៅក្រមស៊ើបអង្កេតជាតិ បានចេញដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន ដោយមូលហេតុថា អ.វ.ត.ក មិនមានយុត្តាធិការបុគ្គលលើ អោ អាន ទេ[1]។ ចំណែកឯ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាដំណោះស្រាយ(ដីកាបញ្ជូនទៅជំនុំជម្រះ)[2]។

2. ដីកាដំណោះស្រាយទាំងពីរនេះ ដែលមួយជាដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន ចេញតែជាភាសាខ្មែរដោយសហចៅក្រមស៊ើបអង្កេតជាតិ និងមានការបកប្រែជាភាសាអង់គ្លេសតាមក្រោយ[3]។ ចំពោះដីកាដំណោះស្រាយ(ដីកាបញ្ជូនទៅជំនុំជម្រះ) របស់ចោទប្រកាន់ជូនរឿងទៅជំនុំជម្រះ ចេញតែជាភាសាអង់គ្លេសដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងមានការបកប្រែជាភាសាខ្មែរតាមក្រោយ[4]។

3. អនុលោមតាមសេចក្តីណែនាំអនុវត្តបានចែងថា គ្រប់ឯកសារទាំងអស់ត្រូវដាក់ជាភាសាខ្មែររួមជាមួយភាសាអង់គ្លេស ឬបារាំង។ នៅក្នុងកាលៈទេសៈពិសេស អង្គជំនុំជម្រះអាចអនុញ្ញាតឲ្យភាគីណាមួយដាក់ឯកសារជាភាសាបារាំង ឬភាសាអង់គ្លេសជាបឋមបាន ប៉ុន្តែបន្ទាប់មកភាគីត្រូវដាក់ឯកសារជាភាសាខ្មែរ ដែលបានបកប្រែរួចឲ្យបានឆាប់រហ័សបំផុត។[5]

4. នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ សហព្រះរាជអាជ្ញាបានដាក់សំណើសុំបន្ថែមពេលវេលាកំណត់សម្រាប់ការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង00៤/២[6]។ ឆ្លើយតបនឹងសំណើសុំនេះ អង្គបុរេជំនុំជម្រះបានបង្គាប់ឲ្យភាគីដាក់សេចក្តីជូនដំណឹងពីបណ្តឹងឧទ្ធរណ៍នឹងដីកាដំណោះស្រាយក្នុងសំណុំរឿង 00៤/២ នៅក្នុងរយៈពេល ១៤ថ្ងៃ បន្ទាប់ពីមានការ

[1] D359 ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន របស់សហចៅក្រមស៊ើបអង្កេតជាតិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

[2] D360 ដីកាដំណោះស្រាយ(ដីកាបញ្ជូនទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

[3] D359 ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន របស់សហចៅក្រមស៊ើបអង្កេតជាតិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ហើយបានបកប្រែជាភាសាអង់គ្លេសរួចរាល់នៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៨។

[4] D360 ដីកាដំណោះស្រាយ(ដីកាបញ្ជូនទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ហើយបានបកប្រែជាភាសាខ្មែររួចរាល់នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨។

[5] សេចក្តីណែនាំអនុវត្តឲ្យដាក់ឯកសារសម្រាប់ប្រើនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, មាត្រា ៧.១ និង ៧.២។

[6] **D359/1** សំណើសុំបន្ថែមពេលវេលាកំណត់សម្រាប់ការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង00៤/២។

ជូនដំណឹងអំពីសំណៅបកប្រែនៃដីកាដំណោះស្រាយទាំងពីរ[7]។ នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨ សហមេធាវីការពារក្តី អោ អាន បានដាក់សំណើសុំពេលវេលា និងចំនួនទំព័រកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ និងបានដាក់ការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍លើ ដីកាដំណោះស្រាយ(ដីកាបញ្ជូនទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ[8]។ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបទៅនឹងសំណើសុំរបស់ អោ អាន[9]។ បន្ទាប់មកអង្គបុរេជំនុំជម្រះ បានសម្រេចអំពីសំណើសុំខាងលើនេះដូចខាងក្រោម[10]៖

- អនុញ្ញាតឲ្យភាគីដាក់បណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយសំណុំរឿង ០០៤/២ រយៈពេល ៤៥ថ្ងៃ ចាប់ពីថ្ងៃទទួលការជូនដំណឹងពីការបកប្រែភាសានៃដីកាដំណោះស្រាយទាំងពីរ
- អនុញ្ញាតឲ្យភាគីដាក់សេចក្តីសន្និដ្ឋានលើបណ្តឹងឧទ្ធរណ៍ចំនួន ១០០ទំព័រ
- អនុញ្ញាតឲ្យភាគីដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួនជាភាសាមួយសិន ចំណែកសំណើបកប្រែភាសានឹងដាក់នៅពេលក្រោយ។

5. នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ សហព្រះរាជអាជ្ញាជាតិ បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ(ដីកាបញ្ជូនទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ សហព្រះអាជ្ញាអន្តរជាតិ បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន របស់សហចៅក្រមស៊ើបអង្កេតជាតិ។

---

[7] ឯកសារ **D359/2** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមពេលវេលាកំណត់សម្រាប់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ របស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨។

[8] ឯកសារ **D360/4** សំណើសុំពេលវេលា និងចំនួនទំព័រកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ របស់សហមេធាវីការពារក្តី អោ អាន និងឯកសារ **D360/5** ការជូនដំណឹងពីបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ(ដីកាបញ្ជូនទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

[9] ឯកសារ **D360/6** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ អោ អាន ស្នើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍របស់គាត់ប្រឆាំងនឹងដីកាដំណោះស្រាយ(ដីកាបញ្ជូនទៅជំនុំជម្រះ) ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ របស់សហព្រះរាជអាជ្ញា។

[10] ឯកសារ **D360/7** សេចក្តីសម្រេចលើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ(បញ្ជូនរឿងទៅជំនុំជម្រះ) របស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨។

6. អនុលោមតាមវិធានផ្ទៃក្នុង[11] វិធាន ៦៧(៥)[12], ៧៣(ក)[13] និង ៧៤(២)[14] សហព្រះរាជអាជ្ញាជាតិ ប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលបានសម្រេចចេញដីកាបញ្ជូន អោ អាន ទៅជំនុំជម្រះ[15]។

## II. ប្រវត្តិនីតិវិធី

7. សហព្រះរាជអាជ្ញា ជាតិ និងអន្តរជាតិ បានពិភាក្សានៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ លើបញ្ហាខ្វែងយោបល់គ្នាទាក់ទងនឹងការប្ដឹងចោទជនសង្ស័យថ្មីបន្ថែមទៀត ផ្សេងពីជនសង្ស័យដែលមានស្រាប់នៅ អ.វ.ត.ក ដើម្បីបញ្ជូនទៅសហចៅក្រមស៊ើបអង្កេតឱ្យបើកការស៊ើបសួរ[16]។ ក្នុងនោះជំហររបស់សហព្រះរាជអាជ្ញាអន្តរជាតិ គឺមានបំណងបញ្ជូនជនសង្ស័យបន្ថែម(សំណុំរឿងលេខ ០០៣ និង ០០៤) ទៅសហចៅក្រមស៊ើបអង្កេតដើម្បីបើកកិច្ចស៊ើបសួរ។ ចំណែកឯសហព្រះរាជអាជ្ញាជាតិ មានជំហរមិនឯកភាពឲ្យមានជនសង្ស័យបន្ថែម ផ្សេងពីជនសង្ស័យដែលមានស្រាប់នៃសំណុំរឿងលេខ ០០១ និង ០០២ ឡើយ[17]។

8. ករណីខ្វែងយោបល់គ្នានេះ ត្រូវបានសហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ បានលើកអំណះអំណាងរៀងៗខ្លួន ដើម្បីដាក់ជូនអង្គបុរេជំនុំជម្រះពិនិត្យ និងសម្រេចតាមនីតិវិធីច្បាប់។ ជាលទ្ធផលអង្គបុរេជំនុំជម្រះមិនទទួលបាននូវសម្លេងគាំទ្រពីចៅក្រមបួនរូបយ៉ាងតិច ដើម្បីធ្វើសេចក្ដីសម្រេចលើការខ្វែងយោបល់គ្នានោះទេ។[18]

---

11 វិធានផ្ទៃក្នុង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

12 វិធាន៦៧(៥) នៃវិធានផ្ទៃក្នុង (ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត) ដែលបានផ្ដល់ជូនសហព្រះរាជអាជ្ញានូវការជូនដំណឹងជាបន្ទាន់អំពីដីកាដំណោះស្រាយ និងការបើកផ្លូវប្ដឹងឧទ្ធរណ៍នឹងដីកាដំណោះស្រាយនេះ។

13 វិធាន៧៣(ក) នៃវិធានផ្ទៃក្នុង (យុត្តាធិការបន្ថែមរបស់អង្គបុរេជំនុំជម្រះ) ដែលបានផ្ដល់សមត្ថកិច្ចដល់អង្គបុរេជំនុំជម្រះនូវសមត្ថកិច្ចពិនិត្យលើបណ្ដឹងឧទ្ធរណ៍ដែលធ្វើឡើងប្រឆាំងនឹងសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត។

14 វិធាន៧៤(២) នៃវិធានផ្ទៃក្នុង (មូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ) ដែលបានផ្ដល់សិទ្ធិជូនសហព្រះរាជអាជ្ញាអាចធ្វើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងគ្រប់ដីការបស់សហចៅក្រមស៊ើបអង្កេត។

15 D360 ដីកាដំណោះស្រាយ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

16 សហព្រះរាជអាជ្ញាអន្តរជាតិ បានបើកការស៊ើបអង្កេតបឋមស្ងាត់ៗដោយឯកឯង ដោយមិនបានជូនដំណឹង និងមិនមានការចូលរួមពីសហព្រះរាជអាជ្ញាជាតិឡើយ។ ការណ៍គឺផ្ទុយនឹងច្បាប់ អ.វ.ត.ក ដែលបានតម្រូវឲ្យសហព្រះរាជអាជ្ញាទាំងពីរធ្វើការរួមជាមួយគ្នានៅក្នុងការិយាល័យសហព្រះរាជអាជ្ញា។

17 កំណត់ហេតុ នៃការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិលើការចោទប្រកាន់ជនសង្ស័យថ្មីបន្ថែម ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨។

18 ឯកសារលេខ D1/1.1 និង D1/1.3 ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ របស់អង្គបុរេជំនុំជម្រះ។

9. អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា នៅពេលដែលអង្គបុរេជំនុំជម្រះ មិនអាចឈានដល់ការធ្វើសេចក្តីសម្រេចលើការខ្វែងយោបល់គ្នាដែលបាននាំយកមកដោះស្រាយនៅចំពោះមុខខ្លួននោះ យោងតាមវិធាន ៧៤.១ នៃវិធានផ្ទៃក្នុង គឺមានន័យថា សហព្រះរាជអាជ្ញាអន្តរជាតិត្រូវបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មី ដើម្បីបើកកិច្ចស៊ើបសួរ ស្របតាមវិធាន ៥៣.១ នៃវិធានផ្ទៃក្នុង។[19]

10. ដោយអនុលោមតាមសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ លើការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា ស្របតាមវិធាន៧១ នៃវិធានផ្ទៃក្នុង[20] នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីបានបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរពាក់ព័ន្ធនឹងសំណុំរឿងលេខ០០៣ និង ០០៤ ទៅសហចៅក្រមស៊ើបអង្កេត ដើម្បីបើកកិច្ចស៊ើបសួរលើសំណុំរឿងទាំងពីរនេះ[21] ជាពិសេសសំណុំរឿងលេខ ០០៤ ដែលក្រោយមកត្រូវបានបំបែកជាសំណុំរឿងលេខ ០០៤/២។

11. នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ទាក់ទងទៅនឹងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម[22]។

12. នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនៃសំណុំរឿងលេខ ០០៤ នៅភូមិភាគកណ្តាល និងការទទួលខុសត្រូវរបស់ជនសង្ស័យ តា អាន[23]។

13. នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ[24]។

---

[19] ឯកសារលេខ D1/1.1 ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ របស់អង្គបុរេជំនុំជម្រះ។

[20] ឯកសារ **D1/1.3** សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន៧១ នៃវិធានផ្ទៃក្នុង ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩។

[21] ឯកសារ **D1/1**
សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីអំពីការដាក់ឯកសារស្តីពីដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី២ និងទី៣ ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩។

[22] ឯកសារ **D27** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ទាក់ទងទៅនឹងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម របស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១។

[23] ឯកសារ **D41** សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនៃសំណុំរឿងលេខ ០០៤ នៅភូមិភាគកណ្តាល និងការទទួលខុសត្រូវរបស់ជនសង្ស័យ តា អាន របស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១។

[24] ឯកសារ **D191** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សា

14. នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេត បានចេញសេចក្ដីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង អោ អាន ដោយជូនដំណឹងភាគីថា មានពេល១៥ថ្ងៃ បន្ទាប់ពីសេចក្ដីជូនដំណឹងនេះ ដើម្បីស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែម និងបង្គាប់ឲ្យបំបែកកិច្ចដំណើរការនីតិវិធី អោ អាន ចេញពីសំណុំរឿង០០៤[25]។ នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពន្យារកាលបរិច្ឆេទកំណត់ចំពោះសំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែម រហូតដល់ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧[26]។

15. ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ មេធាវីការពារក្ដី អោ អាន បានដាក់សំណើសុំដល់អង្គបុរេជំនុំជម្រះ សុំធ្វើមោឃភាពកំណត់ហេតុស្ដាប់ចម្លើយមួយចំនួនរបស់អ្នកស៊ើបអង្កេតបីរូប នៃការិយាល័យសហចៅក្រមស៊ើបអង្កេត[27]។ នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានអនុញ្ញាតតាមសំណើសុំ និងបង្គាប់ឲ្យក្រឡាបញ្ជីបញ្ជូនសំណុំរឿង០០៤/២ ទៅអង្គបុរេជំនុំជម្រះ អនុលោមតាមវិធាន៧៦(៣) នៃវិធានផ្ទៃក្នុង[28]។ នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧ អង្គបុរេជំនុំជម្រះបានច្រានចោលសំណើសុំនេះ[29]។

16. នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៦ មេធាវីការពារក្ដី អោ អាន បានដាក់សំណើសុំឲ្យដាក់ឯកសារមួយចំនួនពាក់ព័ន្ធនឹង Henri Locard ទៅក្នុងសំណុំរឿង[30]។ សហព្រះរាជអាជ្ញា ពុំបានដាក់សារណាឆ្លើយតបទៅនឹងសំណើនេះទេ។

យោនឌ័រ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤។

[25] សំណុំរឿង០០៤/២ ឯកសារD334 សេចក្ដីជូនដំណឹងអំពីការបិទការស៊ើបសួរប្រឆាំង អោ អាន ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦។ សំណុំរឿង ០០៤/២ ឯកសារ D334/1 ដីកាសម្រេចបំបែកសំនុំរឿង អោ អាន ចេញពីសំណុំរឿង០០៤ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦។

[26] សំណុំរឿង ០០៤/២ ឯកសារD340/1 ដីកាសម្រេចលើសំណើរបស់ អោ អាន សុំពន្យារយៈពេលកំណត់ ដើម្បីស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែម ក្រោយពីមានការជូនដំណឹងអនុលោមតាមវិធាន៦៦ នៃវិធានផ្ទៃក្នុង ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦។

[27] សំណុំរឿង ០០៤/២ ឯកសារ D338 សំណើសុំឲ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកំនត់ហេតុស្ដាប់ចម្លើយនានារបស់អ្នកស៊ើបអង្កេតចំនួនបីរូប ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦។

[28] សំណុំរឿង ០០៤/២ ឯកសារ D338/1 ដីកាសម្រេចលើសំណើសុំឲ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកំណត់ហេតុស្ដាប់ចម្លើយនានារបស់អ្នកស៊ើបអង្កេតចំនួនបីរូប ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧។

[29] សំណុំរឿង០០៤/២ ឯកសារ D338/2/5 ដីកាសម្រេចលើសំណើរបស់ អោ អាន សុំមោឃភាពកំណត់ហេតុស្ដាប់ចម្លើយសាក្សី របស់អ្នកស៊ើបអង្កេតចំនួនបីរូប ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧។

[30] សំណុំរឿង០០៤/២ ឯកសារD339 សំណើសុំឲ្យដាក់ឯកសារមួយចំនួនពាក់ព័ន្ធនឹង Henri Locard ទៅក្នុងសំណុំរឿង ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦។

17. នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៦ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ ដើម្បីដាក់ផែនទី និងឯកសារនៃសំណុំរឿង០០២ ទៅក្នុងសំណុំរឿង០០៤/២[31]។ មេធាវីការពារក្ដី មិនបានដាក់សារណាតបនឹងសំណើនេះទេ។

18. នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ មេធាវីការពារក្ដី បានដាក់សំណើបំពេញកិច្ចស៊ើបសួរលើកទី១៣ ស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេត ផ្ដល់ជូនការវិភាគកំហុសមួយចំនួនដែលបានចោទនៅក្នុង កំណត់ហេតុស្ដាប់ចម្លើយ[32]។ សហព្រះរាជអាជ្ញា មិនបានដាក់សារណាឆ្លើយតបនឹងសំណើនេះទេ។

19. នៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញសេចក្ដីសម្រេចលើ *សំណើសុំឲ្យដាក់ឯកសារមួយចំនួនពាក់ព័ន្ធនឹង Henri Locard ទៅក្នុងសំណុំរឿង* និងសេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរដើម្បីដាក់ផែនទី និង ឯកសារនៃសំណុំរឿង០០២ ទៅក្នុងសំណុំរឿង០០៤/២[33]។

20. នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេត បានចេញដីកាសម្រេចលើសំណើសុំ បំពេញកិច្ចស៊ើបសួរលើកទី១៣ របស់ អោ អាន[34]។

21. នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេត បានចេញសេចក្ដីជូនដំណឹងលើកទី២ អំពីការបិទកិច្ចស៊ើបសួរប្រឆាំង អោ អាន ហើយបានជូនដំណឹងដល់ភាគីថា នឹងមិនអនុញ្ញាតផ្ដល់ ពេលវេលាបន្ថែម សម្រាប់សំណើសុំបំពេញកិច្ចស៊ើបសួរឡើយ បន្ទាប់ពីចេញសេចក្ដីជូនដំណឹង លើកទី២នេះ ដោយសារតែវិធានផ្ទៃក្នុងមិនមានចែងតម្រូវបែបនេះ[35]។

---

[31] សំណុំរឿង០០៤/២ ឯកសារ D342 សមណើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរដើម្បីដាក់ផែនទី និងឯកសារនៃសំណុំរឿង០០២ ទៅក្នុងសំណុំរឿង០០៤/២ ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៦។

[32] សំណុំរឿង០០៤/២ ឯកសារ 345 សមណើសុំបំពេញកិច្ចស៊ើបសួរលើកទី១៣ របស់ អោ អាន ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧។

[33] សំណុំរឿង០០៤/២ ឯកសារ D339/1 ដីកាសម្រេចលើសមនើសុំដាក់ឯកសារមួយចំនួនពាក់ព័ន្ធនឹង Henri Locard ទៅក្នុងសំណុំរឿង ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦។ សំណុំរឿង០០៤/២ ឯកសារ D342/1 ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរដើម្បីដាក់ផែនទី និងឯកសារនៃសំណុំរឿង០០២ ទៅក្នុងសំណុំរឿង០០៤/២ ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦។

[34] សំណុំរឿង ០០៤/២ ឯកសារ D345/1 ដីកាសម្រេចលើសំណើសុំបំបេញកិច្ចស៊ើបសួរលើកទី១៣ របស់ អោ អាន ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧។

[35] សំណុំរឿង០០៤/២ ឯកសារ D334/2 សេចក្តីជូនដំនឹងលើកទី២ អំពីការបិទការស៊ើបសួរប្រឆាំង អោ អាន ថ្ងៃតី ២៩ ខែមីនា ឆ្នាំ២០១៧។

22. នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៧ មេធាវីការពារក្តីបានដាក់បណ្តឹងឧទ្ធរណ៍ នៅចំពោះមុខអង្គបុរេជំនុំជម្រះ ប្រឆាំងការជូនដំណឹងមុនរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អំពីការបកស្រាយលើ "ការវាយប្រហារទៅលើប្រជាជនស៊ីវិល" នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់រដ្ឋ ឬរបបនោះ[36]។

23. នៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៧ មេធាវីការពារក្តីបានដាក់សំណើដល់អង្គបុរេជំនុំជម្រះសុំធ្វើមោឃកិច្ចស៊ើបសួរទាំងស្រុង ឬផ្អាកកិច្ចស៊ើបសួររហូតដល់ពេលដែលមេធាវីការពារក្តី អាចអនុវត្តកិច្ចស៊ើបសួរដោយខ្លួនឯង និងសុំដាក់ពាក្យឡើងវិញនូវសំណើសុំបំពេញកិច្ចស៊ើបសួររបស់ខ្លួន[37]។ នៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបដិសេធសំណើសុំមោឃភាព[38]។ នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧ មេធាវីការពារក្តីបានដាក់ការជូនដំណឹងស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណើសុំមោឃភាព[39]។

24. នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេត បានបញ្ជូនសំណុំរឿងមកសហព្រះរាជអាជ្ញាដើម្បីចេញដីកាសន្និដ្ឋានស្ថាពរ[40]។ សហព្រះរាជអាជ្ញាជាតិ បានដាក់ដីកាសន្និដ្ឋានស្ថាពរនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧ ដោយបានស្នើឲ្យលើកលែងចោទប្រកាន់លើ អោ អាន ដោយមូលហេតុថា អោ អាន មិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ទេ[41]។ សហព្រះរាជ

[36] សំណុំរឿង ០០៤/២ ឯកសារ D347.1 ការជូនដំណឹងស្តីពីការបកស្រាយលើ"ការវាយប្រហារទៅលើប្រជាជនស៊ីវិល" នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធរបស់របបឬរដ្ឋនោះ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧។ សំណុំរឿង ០០៤/២ ឯកសារ D347.1/3 បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ស្តីពីការបកស្រាយ "ការវាយប្រហារទៅលើប្រជាជនស៊ីវិល" នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់របបនោះ ឬរដ្ឋនោះ ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៧។

[37] សំណុំរឿង ០០៤/២ ឯកសារ D350 សំណើសុំឲ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរ ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៧។

[38] សំណុំរឿង ០០៤/២ ឯកសារ D350/1 ដីកាសម្រេចលើសំណើរបស់ អោ អាន សុំឲ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៧។

[39] សំណុំរឿង ០០៤/២ ឯកសារ D350/1/1 កាជូនដំណឹងស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់ អោ អាន សុំធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ ថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០១៧។

[40] ឯកសារ **D351** ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ អនុលោមតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង របស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧។

[41] ឯកសារ **D351/4** ដីកាសន្និដ្ឋានស្ថាពរទាក់ទងករណី អោ អាន អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង របស់សហព្រះរាជអាជ្ញាជាតិ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧។

អាជ្ញាអន្តរជាតិ បានដាក់ដីកាសន្និដ្ឋានស្ថាពរ នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ ដោយបានស្នើឲ្យសហចៅក្រមស៊ើបអង្កេតបញ្ជូន អោ អាន ទៅជំនុំជម្រះចំពោះបទចោទដែលបានបង្ហាញនៅក្នុងដីកាសន្និដ្ឋានទាំងអស់[42]។

25. នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ សហមេធាវីការពារក្តី អោ អាន បានដាក់ចម្លើយតបដោយបានស្នើថា បទចោទលើ អោ អាន គួរត្រូវលើកលែង ដោយផ្អែកលើមូលដ្ឋានថា ដីកាសន្និដ្ឋាន និងការបំពេញកិច្ចទាំងអស់ដែលបានអនុវត្តនាពេលកន្លងមក មិនមានសុពលភាពទេ សហចៅក្រមស៊ើបអង្កេត មិនអាចការពារសុច្ចរិតភាព និងភាពយុត្តិធម៌នៃកិច្ចស៊ើបសួរបានឡើយ ហើយ អ.វ.ត.ក មិនមានយុត្តាធិការបុគ្គលលើ អោ អាន ទេ ព្រមទាំងមិនមានភស្តុតាងគ្រប់គ្រាន់ដែលត្រូវចោទប្រកាន់ អោ អាន បញ្ជូនទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មដែលបានដាក់ជាបទចោទទេ[43]។

## III. សារណា

## ការកកើតបក្សកុម្មុយនីស្តកម្ពុជា

26. ឫសគល់នៃបក្សកុម្មុយនីស្តកម្ពុជា អាចនឹងមានប្រភពចេញមកពីបក្សកុម្មុយនីស្តឥណ្ឌូចិន ដែលបានបង្កើតឡើងកាលពីឆ្នាំ១៩៣០។ នៅក្នុងឆ្នាំ១៩៥១ បក្សកុម្មុយនីស្តឥណ្ឌូចិនត្រូវបានរំលាយចោល ហើយបន្ទាប់មក អង្គការបដិវត្តដាច់ដោយឡែកពីគ្នា ត្រូវបានបង្កើតឡើងសម្រាប់ប្រទេសវៀតណាម ឡាវ និងកម្ពុជា ដោយបក្សថ្មីនៅកម្ពុជាមានឈ្មោះថា បក្សប្រជាជនបដិវត្តខ្មែរ។ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦០ បក្សប្រជាជនបដិវត្តខ្មែរ ត្រូវបានប្តូរឈ្មោះទៅ ជាបក្សពលករកម្ពុជា ហើយសមាជបក្សលើកដំបូងត្រូវបានធ្វើឡើងនៅភ្នំពេញ ដើម្បី សម្រេចអំពី“មាគ៌ាយុទ្ធសាស្ត្រ និងយុទ្ធវិធីរបស់បក្ស”។ មាគ៌ាមួយក្នុងចំណោមមាគ៌ា សំខាន់ៗដែលបានទទួលការឯកភាពនៅក្នុងសមាជនោះ គឺការសម្រេចប្រើប្រាស់ “អំពើហិង្សាប្រដាប់អាវុធ” បន្ថែមពីលើសកម្មភាពនយោបាយ “ដើម្បីវាយរំលំពួកសក្តិភូមិ ពួកនាយទុន និងពួកប្រតិកិរិយានៅកម្ពុជា”។ បក្សក៏បានសម្រេចនៅដើមដំបូងនេះថាតំបន់ជនបទគឺជា “មូលដ្ឋានយ៉ាងសំខាន់សម្រាប់បដិវត្ត” ហើយទីក្រុង គឺជា “ប្រភពនៃវណ្ណៈជិះជាន់ និងពួកចក្រពត្តិ ជាទីកន្លែងដែលខ្មាំងបដិវត្តអាចប្រមូលអំណាចដើម្បីកៀបសង្កត់យើង”។ មានមនុស្សចំនួនប្រហែល២០នាក់ បានចូលរួមក្នុងសមាជនេះ ដែលក្នុងនោះមាន

[42] ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់ទាក់ទងករណី អោ អាន អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង របស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧។

[43] ឯកសារ **D351/6** ចម្លើយតបរបស់ អោ អាន ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧។

នួន ជា (អនុលេខាបក្ស ដែលបានទទួលការបោះឆ្នោតតែងតាំង) សាឡុត ស ហៅ ប៉ុល ពត (សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍) អៀង សារី និង សោ ភឹម (សមាជិកបម្រុងនៃគណៈកម្មាធិការអចិន្ត្រៃយ៍) និង វន វេត។ បន្ទាប់ពីពេលអនុម័តមាគ៌ាបក្សថ្មីនេះ សមាជិកបក្សទាំងអស់ត្រូវ "ដាក់ពាក្យសុំចូលបក្សម្តងទៀត"។

27. បន្ទាប់ពីពេលចាប់ខ្លួន និងប្រហារជីវិតលេខាបក្សពលករកម្ពុជាឈ្មោះ ទូ សាមុត នៅឆ្នាំ១៩៦២ សមាជលើកទី២របស់បក្ស ត្រូវបានធ្វើឡើងនៅចុងខែកុម្ភៈ ឆ្នាំ១៩៦៣ ដែលកាលណោះ សាឡុត ស បានក្លាយខ្លួនជាលេខាបក្សថ្មី ចំណែក នួន ជា នៅបន្តធ្វើជាអនុលេខាបក្សដដែល។ សមាជនេះត្រូវបានធ្វើឡើងនៅផ្លូវហ្សាលដឺហ្គោលទីក្រុងភ្នំពេញ ហើយអ្នកចូលរួមគឺជាមនុស្សមួយក្រុមតូច ដែលក្នុងនោះមាន អៀង សារី និង សោ ភឹម (អ្នកទាំងពីរ ត្រូវបានបោះឆ្នោត ជ្រើសតាំងជាសមាជិកពេញសិទ្ធិនៃគណៈអចិន្ត្រៃយ៍) តា ម៉ុក វន វេត សុន សេន វស់ ញឹម និង គង់ សុផល។ បន្ទាប់មកក្នុងឆ្នាំ១៩៦៣ បន្ទាប់ពីរបបសម្តេចសីហនុ បានចេញផ្សាយនូវបញ្ជីឈ្មោះមនុស្សដែលគេស្គាល់ថាជា "អ្នកឆ្វេងនិយម" ចំនួន៣៤រូប ប៉ុល ពត និងមេដឹកនាំបក្សពលករកម្ពុជាមួយចំនួនដែលមានឈ្មោះក្នុងបញ្ជីនោះ រួមទាំង អៀង សារី និង សុន សេន ក៏បានភៀសខ្លួនពីទីក្រុងទៅជ្រកកោននៅឯបន្ទាយយោធាវៀតណាមមួយ នៅតាមបណ្តោយព្រំដែន ហើយក្រោយមកបានបង្កើតមន្ទីរមួយនៅទីនោះឈ្មោះថា មន្ទីរ១០០។ មកដល់ឆ្នាំ១៩៦៥ ប្រពន្ធរបស់ពួកគេដូចជា ខៀវ ប៉ុណ្ណារី អៀង ធីរិទ្ធ និង យុន យ៉ាត បានចូលរួមជាមួយពួកគេ នៅមន្ទីរ១០០នោះ។ ដោយសារអត្តសញ្ញាណរបស់ នួន ជា បន្តស្ថិតនៅជាការសម្ងាត់ ទើបឈ្មោះរបស់គាត់ពុំស្ថិតនៅក្នុងបញ្ជីឈ្មោះមនុស្សទាំង៣៤នាក់នោះ ហើយគាត់បានស្នាក់នៅភ្នំពេញ និងទទួលបន្ទុកប្រតិបត្តិការរបស់បក្សពលករកម្ពុជា ក្នុងទីក្រុង និងតំបន់ជាច្រើន។

28. នៅឆ្នាំ១៩៦៤ បក្សពលករកម្ពុជាបានចាប់ផ្តើមប្រជុំគណៈអចិន្ត្រៃយ៍ជាទៀងទាត់ នៅមន្ទីរ១០០ ហើយនៅខែមករា ឆ្នាំ១៩៦៥ ពួកគេបានឯកភាពលើសេចក្តីសម្រេចមួយដែល បានបដិសេធការ ផ្តល់លទ្ធភាពដល់ "ការផ្លាស់ប្តូរដោយសន្តិវិធី" ទៅកាន់លទ្ធិសង្គមនិយម ហើយបានបញ្ជាក់ អះអាងថា "ជាការចាំបាច់ដែលត្រូវប្រើប្រាស់ហិង្សាបដិវត្ត" ក្នុងការតស៊ូប្រឆាំងនឹងពួកចក្រពត្តិ។ ក្នុងអង្គប្រជុំគណៈមជ្ឈិម កាលពីខែកញ្ញា ឬខែតុលា ឆ្នាំ១៩៦៦ មេដឹកនាំបក្ស ពលករកម្ពុជាបានសម្រេចប្តូរឈ្មោះបក្សទៅជាបក្សកុម្មុយនីស្តកម្ពុជា (ទោះជាគេរក្សាការសម្រេចនោះទុកជាសម្ងាត់រហូតដល់សមាជបក្សលើកក្រោយក្តី) ប្តូរទីតាំងមន្ទីរ១០០ ទៅខេត្តរតនគិរី ហើយភូមិភាគនីមួយៗត្រូវចាប់ផ្តើមរៀបចំការតស៊ូប្រដាប់អាវុធ។ នៅពាក់កណ្តាល ឆ្នាំ១៩៦៧ សមាជិកគណៈអចិន្ត្រៃយ៍

(ប៉ុល ពត នួន ជា អៀង សារី និង សោ ភឹម) បានជួបប្រជុំគ្នានៅមន្ទីរ១០០ និងបានឯកភាពធ្វើការបះបោរជាទូទៅមួយនៅដើមឆ្នាំ១៩៦៨ មិនយូរប៉ុន្មានបន្ទាប់ពីពេលបះបោរ ទីស្នាក់ការគណៈមជ្ឈិមថ្មីមួយ (ឈ្មោះមន្ទីរ១០០ដែរ) ត្រូវបានបង្កើតឡើងក្នុងខេត្តរតនគិរី ចម្ងាយប្រមាណពី២ទៅ៣ គីឡូម៉ែត្រពីមន្ទីរ១០២ មន្ទីរភូមិភាគឦសានដែលត្រូវបានប្រើប្រាស់ដោយ អៀង សារី (គាត់ត្រូវបានតែងតាំងជាលេខាតំបន់)។

29. នៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៦៨ តាមបញ្ជារបស់ នួន ជា កាលពីខែមុន កងកម្លាំងរបស់បក្សកុម្មុយនីស្តកម្ពុជា បានវាយប្រហារបន្ទាយកងទ័ពរបស់រដ្ឋាភិបាលនៅភូមិ បាយដំរាម ភាគខាងត្បូងក្រុងបាត់ដំបង ដោយរឹបអូសបានអាវុធមួយចំនួន។ ក្នុងគ្រាបន្ទាប់មកទៀត កាលបរិច្ឆេទខាងលើនេះត្រូវបានបក្សកុម្មុយនីស្តកម្ពុជាចាត់ទុកថាជា ថ្ងៃកំណើតកងទ័ពបដិវត្តកម្ពុជា។ នៅខែបន្តបន្ទាប់កងកម្លាំងរបស់បក្សកុម្មុយនីស្តកម្ពុជា នៅបានបន្តការវាយប្រហារតាមលក្ខណៈទ័ពព្រៃនៅទូទាំងប្រទេស។

30. នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ សម្តេចនរោត្តមសីហនុ ត្រូវបានឧត្តមសេនីយ៍ លន់ នល់ និងព្រះអង្គម្ចាស់សិរីមតៈ ទម្លាក់ពីតំណែង ហើយពួកគេបានបង្កើតរបបមួយឈ្មោះថា របបសាធារណរដ្ឋខ្មែរ។ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ សម្តេចសីហនុ បានប្រកាសអំពីការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា និងបានអំពាវនាវឱ្យកូនចៅរបស់ទ្រង់បើកយុទ្ធនាការវាយប្រហារតាមក្បួនទ័ពព្រៃ និងឱ្យប្រជាជនស៊ីវិលធ្វើការបះបោរប្រឆាំងនឹងរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ។ សម្ពន្ធភាពមួយត្រូវបានបង្កើតឡើង រវាងសម្តេចសីហនុ និងបក្សកុម្មុយនីស្តកម្ពុជាព្រមទាំងរដ្ឋាភិបាលនិរទេសដែលមានមូលដ្ឋាននៅទីក្រុងប៉េកាំង ដែលមានឈ្មោះថារាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលក្នុងនោះមាន ខៀវ សំផន ជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ និងត្រូវបានប្រកាសជាផ្លូវការ នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧០។ នៅខែសីហា ឆ្នាំ១៩៧០ អៀង ធីរិទ្ធ ត្រូវបានតែងតាំងជាអនុរដ្ឋមន្ត្រីក្រសួងវប្បធម៌ អប់រំយុវជន នៅក្នុងជួររាជរដ្ឋាភិបាលរួបរួមជាតិ។

## មហាសន្និបាតបក្ស

31. លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាបានប្រគល់ "សិទ្ធិអំណាចធំជាងគេបំផុតសម្រាប់ទូទាំងប្រទេស" ទៅឱ្យ "មហាសន្និបាតតំណាងទូទាំងប្រទេស" (ពោលគឺ មហាសន្និបាតបក្ស) ដែលត្រូវបានធ្វើឡើង "រៀងរាល់៤ឆ្នាំម្តង" ដើម្បី (i)"ពិនិត្យ តាមដាន វិនិច្ឆ័យសកម្មភាពរបស់គណៈកម្មាធិការមជ្ឈិមចាស់" (ii)"កំណត់មាគ៌ានយោបាយ និងលក្ខន្តិកៈ" និង(iii)"ជ្រើសតាំងគណៈកម្មាធិការ

មជ្ឈិមថ្មី"។ ដូចដែលបានរៀបរាប់ខាងលើ នៅរយៈកាលមុនសម័យកម្ពុជាប្រជាធិបតេយ្យ មហាសន្និបាតបក្ស ត្រូវបានប្រារព្ធធ្វើនៅឆ្នាំ១៩៦០ ១៩៦៣ និងឆ្នាំ១៩៧១ ដែលមហាសន្និបាតឆ្នាំ១៩៦០ និង១៩៦៣ មានអ្នកចូលរួមចំនួន២០នាក់ ហើយមហាសន្និបាតឆ្នាំ១៩៧១ មានអ្នកចូលរួមប្រមាណ ៦០នាក់។ ក្នុងអំឡុងរយៈកាលសម័យកម្ពុជាប្រជាធិបតេយ្យ មហាសន្និបាតបក្សលើកទី៤ ត្រូវបានប្រារព្ធធ្វើនៅខែមករា ឆ្នាំ១៩៧៦ នៅបុរីកីឡាភ្នំពេញ ហើយគេបានបើកមហាសន្និបាតបក្សលើកទី៥ នៅឆ្នាំ១៩៧៨ ដោយមានការចូលរួមពីមនុស្សចំនួនប្រមាណ៦០នាក់។

## គណៈកម្មាធិការមជ្ឈិម

32. នៅក្នុងរយៈពេលពីមហាសន្និបាតមួយទៅមួយទៀត លក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា បានចាត់ទុកគណៈកម្មាធិការមជ្ឈិមថាជា "អង្គការប្រតិបត្តិការខ្ពស់ជាងគេបំផុតសម្រាប់ទូទាំងប្រទេស"។ គណៈកម្មាធិការមជ្ឈិម មានសមាជិកសរុបទាំងអស់ចំនួន យ៉ាងហោចណាស់ ៣០រូប។ បន្ថែមពីលើសមាជិកនៃគណៈអចិន្ត្រៃយ៍ សមាជិកគណៈមជ្ឈិម រួមមាន លេខាតំបន់ និងភូមិភាគ ដូចជា កែ ពក ម៉ែន សាន ហៅ យ៉ា សំ ប៊ិត និង ព្រីង សារុន លេខាក្រសួង ដូចជា កុយ ធួន មេបញ្ជាការកងពល ដូចជា មាស មុត និង ខៀវ សំផន ដែលបានចាប់ផ្តើមធ្វើជាសមាជិក"ត្រៀម" នៅឆ្នាំ១៩៧១ និងបានក្លាយខ្លួនជាសមាជិកពេញសិទ្ធិ ក្នុងមហាសន្និបាតលើកទី៤ នៅខែមករា ឆ្នាំ១៩៧៦។ គណៈមជ្ឈិម បានជួបប្រជុំគ្នារៀងរាល់៦ខែម្តង។ ភារកិច្ចចាត់តាំងរបស់ខ្លួន តាមលក្ខន្តិកៈរបស់បក្ស គឺជាការ"អនុវត្តមាគ៌ានយោបាយ និងលក្ខន្តិកៈរបស់បក្សនៅក្នុងជួរបក្ស" ណែនាំដល់អង្គការចាត់តាំងរបស់បក្ស តំបន់ និងភូមិភាគ ឲ្យ"អនុវត្តសកម្មភាពស្របតាមមាគ៌ានយោបាយ" និង "គ្រប់គ្រង និងចាត់ចែងកម្មាភិបាល និងបក្ខជនក្នុងបក្សទាំងមូល ព្រមទាំងអង្គការស្នូលទាំងអស់ ដោយក្តាប់ប្រវត្តិរូប ជំហរនយោបាយ សតិអារម្មណ៍ និងចាត់តាំងឲ្យច្បាស់ និងឲ្យជាប់ជានិច្ច"។

## គណៈកម្មាធិការអចិន្ត្រៃយ៍

33. ក្នុងការអនុវត្តជាក់ស្តែង វាគឺជាអនុគណៈកម្មាធិការនៃគណៈមជ្ឈិម ដែលត្រូវគេស្គាល់ថាជាគណៈអចិន្ត្រៃយ៍ ដែលដើរតួនាទីជាអង្គការដែលមានសិទ្ធិអំណាចខ្ពស់ និងផ្តាច់ការជាងគេបំផុតក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា និងរដ្ឋាភិបាលរបបកម្ពុជាប្រជាធិបតេយ្យ។ ខៀវ សំផន បានផ្តល់សក្ខីកម្មថា "ទាំងមាគ៌ានយោបាយ និងដំណើរការធ្វើសេចក្តីសម្រេចសុទ្ធតែ ត្រូវបានបង្កើតឡើង

ដោយគណៈអចិន្ត្រៃយ៍" ហើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច បានគូសបញ្ជាក់ថាគណៈអចិន្ត្រៃយ៍គឺជា "ស្ថាប័នសំខាន់បំផុតនៅក្នុងជួរបក្ស"។[44]

34. គណៈអចិន្ត្រៃយ៍បានបង្កើត ដឹកនាំ និងតាមដានការអនុវត្តន៍រាល់គ្រប់គោលនយោបាយរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងរបស់បក្សកុម្មុយនីស្តកម្ពុជា។ ពិសេស គណៈអចិន្ត្រៃយ៍ជាអ្នកក្តោបក្តាប់គោលនយោបាយទាក់ទិននឹងសន្តិសុខផ្ទៃក្នុង និងខាងក្រៅ ការបរទេស កិច្ចការក្នុងស្រុក ដូចជាការងារហិរញ្ញវត្ថុ ពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សុខាភិបាល និងសង្គមកិច្ច ឃោសនាការ និងការលត់ដំកែប្រែ បក្សកុម្មុយនីស្តកម្ពុជា និងបុគ្គលិករដ្ឋ និងបញ្ហារដ្ឋបាល។ គណៈអចិន្ត្រៃយ៍បានពិភាក្សា និងបានបញ្ជាឲ្យមានការជម្លៀសប្រជាជនដោយបង្ខំក្នុងទ្រង់ទ្រាយធំ ការប្រើប្រាស់ការធ្វើការងារពលកម្មដោយបង្ខំ និងការចាប់ខ្លួន និងការសួរចម្លើយ"ខ្មាំង" បានតាមដានស្ថានភាពរស់នៅរបស់ប្រជាជននៅទូទាំងប្រទេស និងជាអ្នកមានសិទ្ធិអំណាចក្នុងការបញ្ជាឲ្យមានការហោរជីវិតមនុស្សភ្លាមៗ តាមទំនើងចិត្ត។

35. សេចក្តីណែនាំនានារបស់គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ ត្រូវបានបញ្ជូនទៅមន្ទីរភូមិភាគ កងពលយោធា និងតាមក្រសួងនានា បន្ទាប់មកស្ថាប័នទាំងនោះ នឹងធ្វើការផ្សព្វផ្សាយបែងចែកបន្តទៅឲ្យតំបន់ ស្រុក និងថ្នាក់ទាបផ្សេងៗទៀត។ កម្មាភិបាល ប.ក.ក មួយរូបបានបញ្ជាក់នៅក្នុងសម្តីរបស់ខ្លួនថា៖ "គ្រប់យ៉ាង" គឺបានមកពីមជ្ឈិមបក្សទាំងអស់។ មជ្ឈិមបក្សបានផ្តល់នូវការណែនាំយ៉ាងច្បាស់លាស់ នៅក្នុងសេចក្តីណែនាំរបស់ខ្លួន ស្តីពីរបៀបដែលពួកគេត្រូវធ្វើការប្រាស្រ័យទាក់ទង និងប្រតិបត្តិការ។ ឧទាហរណ៍ នៅក្នុងសេចក្តីថ្លែងការណ៍របស់គណៈមជ្ឈិមដែលបានធ្វើនៅខែមិថុនា ឆ្នាំ១៩៧៨ ក្នុងគោលបំណងពិនិត្យគោលនយោបាយរបស់បក្សចំពោះសេរីអា កាហ្សេបេ និងខ្មាំងយួនឡើងវិញ នៅក្នុងសេចក្តីថ្លែងការណ៍នោះ មានផ្តល់នូវការណែនាំដូចតទៅនេះ៖ "ស្នើឲ្យគ្រប់ភូមិភាគ តំបន់ និងកងយោធាទាំងអស់ ឲ្យយកការណែនាំខាងលើនេះ ទៅរៀនសូត្រ និងដើម្បីចាត់ឲ្យមានអង្គប្រជុំនៅតាមបក្ស រចនាសម្ព័ន្ធសំខាន់ៗនៅតាមក្រសួង និងមន្ទីរក្នុងកងយោធា សហករណ៍ រោងចក្រ និងការដ្ឋានរៀងៗខ្លួន ដើម្បីផ្សព្វផ្សាយឲ្យប្រជាជនទាំងអស់ បានដឹងពីគោលនយោបាយរបស់បក្ស ចាប់ពីពេលនេះ រហូតដល់ដំណាច់ឆ្នាំ ១៩៧៨ សូមស្នើឲ្យ សហករណ៍ រោងចក្រ ការដ្ឋាន កងនៅតាមកន្លែងនីមួយៗ ឲ្យរៀនសូត្រ

[44] **D6/1/91** កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២00៨ ទំព័រ៣។ **D6/1/1073** ឯកសារនៃការដាក់ចម្លើយរបស់ជនត្រូវចោទឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ជាអតីតប្រធានមន្ទីរសន្តិសុខ ស-២១ ដែលបានធ្វើការឆ្លើយតបទៅនឹងសំណួរជាលាយលក្ខណ៍អក្សររបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២00៨ ទំព័រ៣។

និងរៀបចំអង្គប្រជុំ ឲ្យបានពី៥ ទៅ៦ដង”។ សមាជិកគណៈអចិន្ត្រៃយ៍ ក៏បានធ្វើការត្រួតពិនិត្យនៅតាមភូមិភាគនានា ដោយមានពេលខ្លះ សមាជិកគណៈអចិន្ត្រៃយ៍ទាំងនោះ បានធ្វើដំណើរជាក្រុមទៀតផង។

## ការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា

36. ចាប់តាំងពីថ្ងៃដំបូងដែលបក្សកុម្មុយនីស្តកម្ពុជា (ប.ក.ក) ចូលគ្រប់គ្រងប្រទេស ប្រជាជនបីលាននាក់ ដែលរស់នៅក្នុងទីក្រុងភ្នំពេញ និងតាមទីប្រជុំជននានា ត្រូវបានគេជម្លៀសចេញពីផ្ទះសម្បែងរបស់ខ្លួន និងបង្ខំឲ្យចេញទៅតាមទីជនបទជាទីកន្លែងប្រជាជនទាំងអស់ ត្រូវបានបង្ខាំងឱ្យធ្វើការងារកសិកម្មនៅក្នុងសហករណ៍ និងការដ្ឋានផ្សេងៗទៀត។

37. បក្សកុម្មុយនីស្តកម្ពុជា បានបង្កើតសង្គមថ្មីមួយ ដែលបានប្រែក្លាយប្រជាពលរដ្ឋកម្ពុជាឱ្យទៅជាទាសករ បានអនុវត្តការគ្រប់គ្រងទាំងស្រុងលើជីវិតប្រជាពលរដ្ឋកម្ពុជា និងបានដកហូតស្ទើរគ្រប់សិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានរបស់ប្រជាពលរដ្ឋ។ ទ្រព្យសម្បត្តិឯកជនត្រូវបានរឹបអូសរូបិយវត្ថុត្រូវបានលុបបំបាត់ចោល ទីផ្សារ អាជីវកម្ម សាលារៀន និងវត្តអារាម ត្រូវបានបិទទ្វារ។ ប្រជាពលរដ្ឋកម្ពុជាលែងត្រូវបានអនុញ្ញាតឱ្យរួមរស់ជាមួយនឹងគ្រួសារក្នុងផ្ទះសម្បែង ឬគោរពសាសនារបស់ខ្លួនទៀតឡើយ ហើយត្រូវបានដាក់ឱ្យស្ថិតនៅក្រោមគោលនយោបាយនៃការគាបសង្កត់ផ្លូវភេទដែលពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ និងការបង្ខំឱ្យមានផ្ទៃពោះ។ ប្រជាពលរដ្ឋកម្ពុជាមិនត្រូវបានអនុញ្ញាតឱ្យចាកចេញពីប្រទេស ឬដើរហើរនៅក្នុងប្រទេស ហើយបានទទួលរងនូវការបំពានផ្លូវចិត្ត តាមរយៈការបំពាក់បំប៉ន ការទិតៀន និងស្វ័យទិតៀន ដែលគេអនុវត្តក្រោមការគម្រាមកំហែងដាក់ទណ្ឌកម្មធ្ងន់ធ្ងរ។ បក្សកុម្មុយនីស្តកម្ពុជា បានបង្កើតរដ្ឋមួយ គឺរដ្ឋកម្ពុជាប្រជាធិបតេយ្យ ដែលពុំមានសភា ឬប្រព័ន្ធតុលាការដំណើរការ និងជារដ្ឋមួយដែល បក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តការគ្រប់គ្រងដោយគ្មានក្តីមេត្តា។

38. បក្សកុម្មុយនីស្តកម្ពុជា បានជម្លៀស ហើយបំបែកប្រជាជនដែលបក្សបានកំណត់មុខសញ្ញាចេញជាក្រុម ដូចជា ក្រុមមន្ត្រី និងទាហាននៃរបបសាធារណរដ្ឋខ្មែរដែលត្រូវបានផ្តួលរំលំ និងក្រុម “ខ្មាំងវណ្ណៈ” របស់បក្ស គឺពួកនាយទុន ពួកសក្តិភូមិ និងពួកអនុធន។ ក្រុមទាំងនេះត្រូវបានសម្លាប់ចោលដោយមិនទទួលបានការជំនុំជម្រះ ហើយអ្នកដែលត្រូវបានជម្លៀសដែលនៅសល់ (ដោយកំណត់ថាជា “ប្រជាជនថ្មី”) ត្រូវបានគេដាក់ឱ្យទៅជាទាសករនៅក្នុងសហករណ៍ជាមួយនឹងប្រជាជនមូលដ្ឋាន និងក្រោយមកនៅតាមគម្រោងជីកប្រឡាយធំៗ និងគម្រោងកសាងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងរបបនេះ។

39. ក្នុងពេលដែលត្រូវបានគេដាក់ឱ្យទៅជាទាសករ ប្រជាពលរដ្ឋកម្ពុជាបានទទួលរងនូវស្ថានភាពបែបអមនុស្សធម៌ ដោយរួមមាន ពលកម្មបាក់កម្លាំង ការបដិសេធមិនឱ្យមានការសម្រាក ការមិនផ្ដល់អាហារគ្រប់គ្រាន់ ការមិនផ្ដល់ការថែទាំសុខភាពគ្រប់គ្រាន់ ការមិនផ្ដល់ជម្រកសមរម្យ និងការរំលោភផ្លូវកាយ និងផ្លូវចិត្ត។ អ្នកដែលត្រូវបានចោទប្រកាន់ថាមិនគោរពតាម មិនថាប្រភេទណាក៏ដោយ បានទទួងរងទណ្ឌកម្មធ្ងន់ធ្ងរ រួមមាន ការធ្វើឱ្យស្ថានភាពការងារកាន់តែធ្ងន់ធ្ងរឡើង ការវាយដំ ការដកហូតរបបអាហារ ការលត់ដំខ្លួន ការចាប់ខ្លួន ការរងទារុណកម្ម និងការសម្លាប់ចោល។

40. នៅពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ បក្សកុម្មុយនីស្ដកម្ពុជា បានបង្កើត និងដំណើរការជំរំអប់រំកែប្រែ និងមន្ទីរសន្តិសុខជាង២៦០កន្លែង ដែលបង្កើតជាយន្តការសំខាន់នៃផែនការឧក្រិដ្ឋរបស់បក្សក្នុងការកំណត់ បង្ក្រាប និងកម្ទេច "ខ្មាំង" នៃរបបនេះ។ ខ្មាំងទាំងនេះ រួមមានបុគ្គលទាំងឡាយដែលមានជាប់ប្រវត្តិសង្ស័យ និងបុគ្គលទាំងឡាយដែលបក្សមើលឃើញថាមិនស្មោះត្រង់។ "ខ្មាំង" សំខាន់ៗ ត្រូវបានកំណត់តាមមធ្យោបាយពីរជាចម្បង។ ប្រជាជនដែលរស់នៅក្នុងសហករណ៍ ឬការដ្ឋាន ត្រូវបានបក្សកុម្មុយនីស្ដកម្ពុជា តាមដានយ៉ាងស្អិត តាមរយៈការធ្វើប្រវត្តិរូប និង "វគ្គទិតៀន" ប្រចាំថ្ងៃ។ បន្ថែមពីនេះ បុគ្គលដែលត្រូវបានយកទៅមន្ទីរសន្តិសុខ ត្រូវបានសួរចម្លើយដោយប្រើទារុណកម្មដើម្បីទាញយកចម្លើយសារភាពលម្អិត ដែលចោទប្រកាន់អ្នកផ្សេងថាជា "ខ្សែ" ខ្មាំង។ ប្រជាពលរដ្ឋរាប់ម៉ឺននាក់ ត្រូវបានចាប់ខ្លួន ឃុំខ្លួន ធ្វើទារុណកម្ម និងសម្លាប់ចោលដោយខុសច្បាប់នៅតាមមន្ទីរសន្តិសុខទាំងនេះក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។

## រចនាសម្ព័ន្ធរដ្ឋបាលមូលដ្ឋាន

### ភូមិភាគ

41. ក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានភូមិភាគចំនួន៦[45] រួមមាន ភូមិភាគនិរតី (៤០៥) ភូមិភាគបស្ចិម (៤០១) ភូមិភាគពាយ័ព្យ (៥៦០) ភូមិភាគកណ្ដាល (អតីតភូមិភាគឧត្តរ) ភូមិភាគឦសាន (១០៨)

---

[45] **D6/1/975** ឯកសារសៀវភៅក្រោមចំណងជើងថា "ភូមិសាស្ត្រកម្ពុជាប្រជាធិបតេយ្យផ្នែកនយោបាយ" របស់ក្រសួងសិក្សាធិការកម្ពុជាប្រជាធិបតេយ្យ បោះពុម្ពផ្សាយលើកទី១ នាឆ្នាំ១៩៧៧ ទំព័រ៣ និងទំព័រ១០។ **D6/1/532** ឯកសារសៀវភៅក្រោមចំណងជើងថា "ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជាពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ" និពន្ធដោយ ខៀវ សំផន ចេញផ្សាយនាខែតុលា ឆ្នាំ២០០៧ ទំព័រ២១៩។ **D6/1/53** ឯកសារសៀវភៅក្រោមចំណងជើងថា "ក្បាលយួនខ្លួនខ្មែរ" ភូមិភាគបូព៌ានៃកម្ពុជា ឆ្នាំ១៩៧៥-១៩៧៨ និពន្ធដោយលោក បិន ឃៀនិន មជ្ឈមណ្ឌលសិក្សាអាស៊ីអាគ្នេយ៍ សាកលវិទ្យាល័យម៉ូណាស់ ទំព័រ២។ **D6/1/460** ឯកសារជាផែនទីកម្ពុជាប្រជាធិបតេយ្យនៃរបបកម្ពុជាប្រជាធិបតេយ្យ ផែនទីនេះត្រូវបានបោះពុម្ពផ្សាយដោយក្រសួងសិក្សាធិការកម្ពុជាប្រជាធិបតេយ្យ នាឆ្នាំ១៩៧៦ ទំព័រ១។

និងភូមិភាគបូព៌ា(២០៣)។ក្រៅពីនេះមានតំបន់ស្វយ័តមួយចំនួន[46] រួមមានតំបន់មណ្ឌលគិរី (១០៥) តំបន់ក្រចេះ (៥០៥) តំបន់ព្រះវិហារ (១០៣) និងតំបន់សៀមរាប-ឧត្តរមានជ័យ (១០៦)។

42. ភូមិភាគត្រូវបែងចែកជាតំបន់ ដែលតំបន់បានបែងចែកទៅជាស្រុក។ ស្រុកមួយមានឃុំមួយចំនួន ដែលឃុំមួយៗ មានភូមិជាច្រើន។ ភូមិភាគ តំបន់ ស្រុក ឃុំ ភូមិ គឺជាឧបករណ៍សម្រាប់អនុវត្តនូវមាគ៌ាណែនាំរបស់មជ្ឈិមបក្ស និងគណៈអចិន្ត្រៃយ៍ បក្សកុម្មុយនីស្តកម្ពុជា នៅទូទាំងប្រទេស។

43. ភូមិភាគនីមួយៗត្រូវបានដឹកនាំដោយលេខាភូមិភាគមួយរូប អនុលេខាភូមិភាគ ព្រមទាំងសមាជិកគណៈភូមិភាគ។ ចំពោះតំបន់ស្វយ័តក៏ដូចគ្នានេះដែរ។ លេខាភូមិភាគជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស ហើយសមាជិកគណៈភូមិភាគមួយចំនួនតូច អាចជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស។

## ភូមិភាគនិរតី

44. ភូមិភាគនិរតីមានតំបន់ចំនួន៤ រួមមាន តំបន់៣៥ តំបន់១៣ តំបន់៣៣ និងតំបន់២៥។ ភូមិភាគនិរតីមានលេខាភូមិភាគឈ្មោះ អ៊ុង ជឿន ហៅ ឈិត ជឿន ហៅ តា ម៉ុក ជាសមាជិកគណៈអចិន្ត្រៃយ៍បក្ស។ តា ម៉ុក ត្រូវបានតែងតាំងជាលេខាភូមិភាគនេះពេលមួយរយៈពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។

## ភូមិភាគកណ្ដាល

45. ប្រហែលពីរ ឬបីខែក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ភូមិភាគឧត្តរ ត្រូវបានអង្គការប្ដូរឈ្មោះទៅជាភូមិភាគកណ្ដាល។ ភូមិភាគកណ្ដាលនេះ មានតំបន់ចំនួន ៣ រួមមាន តំបន់៤១ តំបន់ ៤២ និង តំបន់៤៣។

46. ដំបូង ភូមិភាគឧត្តរនេះមានលេខាភូមិភាគឈ្មោះ កុយ ធួន ហៅធុច ហៅឃួន ហើយ កែ ពក ជាអនុលេខាភូមិភាគ។ កែ ពក ត្រូវបានអង្គការចាត់តាំងឲ្យធ្វើជាលេខាភូមិភាគឧត្តរ បន្ទាប់ពី កុយ ធួន ត្រូវបានតែងតាំងជាលេខាគណៈកម្មាធិការពាណិជ្ជកម្មនៅភ្នំពេញ។

47. ក្នុងគណៈកម្មាធិការភូមិភាគកណ្ដាល មាន កែ ពក ជាលេខាភូមិភាគ អាង ជាអនុលេខា និង ស៊ីម ជាសមាជិកគណៈភូមិភាគ។ សាក្សីឈ្មោះ ទេព ប៉ូច អតីតលេខាស្រុកបារាយណ៍ បាននិយាយថា

---

[46] **D6/1/975** ឯកសារសៀវភៅក្រោមចំណងជើងថា "ភូមិសាស្ត្រកម្ពុជាប្រជាធិបតេយ្យផ្នែកនយោបាយ" របស់ក្រសួងសិក្សាធិការកម្ពុជាប្រជាធិបតេយ្យ បោះពុម្ពផ្សាយលើកទី១ នាឆ្នាំ១៩៧៧ ទំព័រ១០។ **D6/1/460** ឯកសារជាផែនទីកម្ពុជាប្រជាធិបតេយ្យនៃរបបកម្ពុជាប្រជាធិបតេយ្យ ដោយក្រសួងសិក្សាធិការកម្ពុជាប្រជាធិបតេយ្យ នាឆ្នាំ១៩៧៦។

"*តាមខ្ញុំដឹង ឈ្មោះ ស៊ីម ជាអនុម្នាក់របស់ កែ ពក ហើយឈ្មោះ ចន ដែលជាលេខាតំបន់៤៣ ក៏ជាអនុលេខាម្នាក់ដែរ*"។[47] សមាសភាពក្នុងគណៈកម្មាធិការភូមិភាគនេះ រួមមាន កែ ពក ជាលេខាភូមិភាគ ស្រេង ជាអនុលេខា តុល, ចន និងអឿន ជាសមាជិកគណៈភូមិភាគ។[48]

48. នៅពេលមានការមកដល់របស់កម្មាភិបាលនិរតី សមាសភាពនៃគណៈកម្មាធិការភូមិភាគកណ្ដាលត្រូវបានផ្លាស់ប្ដូរ រួមមាន **អោ អាន** ជាអនុលេខាភូមិភាគ អឿន ស៊ីម និង យុត ជាសមាជិក។ សាក្សីឈ្មោះ គុច វ៉ា បាននិយាយថា "តួនាទី តា **អាន** ជាអនុលេខាភូមិភាគ គឺត្រូវបានប្រកាសជាផ្លូវការនៅក្នុងសន្និបាតក្នុងភូមិភាគ"។

## ភូមិភាគបស្ចិម

49. ភូមិភាគបស្ចិមមានតំបន់ចំនួន៤ រួមមាន តំបន់៣១ តំបន់៣២ តំបន់៣៧ និងតំបន់១១។ ភូមិភាគបស្ចិម មានលេខាភូមិភាគឈ្មោះ ជូ ជេត ហៅ ស៊ី ជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស។

## ភូមិភាគពាយ័ព្យ

50. ភូមិភាគពាយ័ព្យមានតំបន់ចំនួន៦ រួមមាន តំបន់២ តំបន់៣ តំបន់៤ និងតំបន់៥ តំបន់៥៦ និងតំបន់៧។ ភូមិភាគពាយ័ព្យ មានលេខាភូមិភាគឈ្មោះ រស់ ញឹម ជាសមាជិកជាសមាជិកបម្រុង។

## ភូមិភាគឥសាន

51. ភូមិភាគឥសានមានតំបន់ចំនួន៤ រួមមាន តំបន់១០១ តំបន់១០២ តំបន់១០៤ និងតំបន់១០៧។ ភូមិភាគឥសាន មានលេខាភូមិភាគឈ្មោះ ម៉ែន សាន ហៅ យ៉ា ជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស។

## ភូមិភាគបូព៌ា

52. ភូមិភាគបូព៌ាមានតំបន់ចំនួន៥ រួមមាន តំបន់២០ តំបន់២១ តំបន់២២ តំបន់២៣ និងតំបន់២៤។ ភូមិភាគបូព៌ា មានលេខាភូមិភាគឈ្មោះ សោ ភឹម ជាសមាជិកពេញសិទ្ធិរបស់គណៈកម្មាធិការអចិន្ត្រៃយ៍។

---

[47] **D117/19** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីឈ្មោះ ទេព ប៉ូច ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ទំព័រ៤។

[48] **D6/1/385** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីឈ្មោះ ស៊ូ សឿន ឈ្មោះហៅក្រៅ សឿន ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ៩។ **D1/3/16/1** ឯកសារជាសំណេរដោយដៃស្ដីពីប្រវត្តិតស៊ូរបស់ កែ ពក អតីតលេខាភូមិភាគកណ្ដាល គិតពីឆ្នាំ១៩៧៥ រហូតមកដល់បច្ចុប្បន្ន ទំព័រ១០។

# សាវតាររបស់ អោ អាន

53. **អោ អាន** មានឈ្មោះពីកំណើតជា ឱម យឿង និងកើតនៅឆ្នាំ ១៩៣៣ ឬឆ្នាំ ១៩៣៦ នៅភូមិតាំងស្វាយ ឃុំពាម ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។ គាត់បានបួសជាព្រះសង្ឃប្រហែលពីឆ្នាំ ១៩៥៤ ដល់ឆ្នាំ ១៩៦០។ គាត់បានចាកសិក្ខាបទដោយសារមានជំងឺនៅឆ្នាំ ១៩៦០។ ក្រោយមកគាត់បានធ្វើជាកសិករធ្វើស្រែនៅស្រុកកំណើតរបស់គាត់។

54. នៅក្រោយរដ្ឋប្រហាររបស់ លន់ នល់ ប្រឆាំងនឹងសម្តេចសីហនុ នៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧០ **អោ អាន** បានចូលរួមក្នុងចលនាតស៊ូមួយដែលដឹកនាំដោយ "តា ១៥" ដែលក្រោយមក **អោ អាន** បានដឹងថាតាមពិតជាតា ម៉ុក។ ដំបូង គាត់ត្រូវបានចាត់ឲ្យចូលក្នុងក្រុមឃោសនាការដែលមានសមាជិក ១២ នាក់។ នៅឆ្នាំ ១៩៧១ តា ម៉ុក បានតែងតាំង **អោ អាន** ជាលេខាធិការស្រុកកណ្តាលស្ទឹងដែលស្ថិតនៅភាគខាងត្បូងទីក្រុងភ្នំពេញ។ ក្រោយមកមិនយូរប៉ុន្មាន តា ម៉ុក បានតែងតាំង **អោ អាន** ជាមេបញ្ជាការកងពលធំលេខ ១១ នៃយោធាខ្មែរក្រហម។ នៅពេលតែងតាំងនោះ កងពលធំលេខ ១១ គឺជាផ្នែកនៃភូមិភាគនិរតី ប៉ុន្តែក្រោយមកត្រូវបានដាក់ជាផ្នែកមួយនៃភូមិភាគពិសេស។ **អោ អាន** នៅបន្តបម្រើការនៅកងពលធំលេខ ១១ ក្នុងស្រុកកណ្តាលស្ទឹងដដែល រហូតដល់មានការវាយសម្រុកចុងក្រោយរបស់ខ្មែរក្រហមចូលទីក្រុងភ្នំពេញ។

55. **អោ អាន** និងកងពលធំលេខ ១១ បានចូលរួមក្នុងការវាយប្រហារទីក្រុងភ្នំពេញ នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដោយធ្វើដំណើរឡើងទៅផ្លូវជាតិលេខ ៣ កាត់តាមចោមចៅ ឆ្ពោះទៅទីក្រុង។ រយៈពេលតិចជាងមួយខែបន្ទាប់ពីការគ្រប់គ្រងទីក្រុងភ្នំពេញ **អោ អាន** ត្រូវបានកោះហៅឲ្យទៅជួបប្រជុំជាមួយ សុន សេន ដែលនៅក្នុងកិច្ចប្រជុំនោះ គាត់ត្រូវបានតែងតាំងជាសមាជិកគណៈកម្មាធិការសម្រាប់តំបន់ ២៥ ក្នុងភូមិភាគនិរតី។ គាត់ត្រូវបានតែងតាំងក្នុងពេលតែមួយជាលេខាធិការស្រុកស្អាង។

56. នៅដើមឆ្នាំ១៩៧៦ តា ម៉ុក បានផ្ទេរ **អោ អាន** ទៅតំបន់ ៣៥ (កំពត) ដែលនៅទីនោះ គាត់បានបម្រើការនៅក្នុងគណៈកម្មាធិការតំបន់នេះ។ គាត់ក៏ទទួលខុសត្រូវផងដែរលើស្រុកស្រែក្នុង ឈូក និងកោះស្លា។ នៅក្នុងតំបន់ ៣៥ **អោ អាន** បានមើលការខុសត្រូវការងារនៅការដ្ឋានសាងសង់ទំនប់នានាតាមផែនការដែលផ្តល់ដោយ និងនៅក្រោមសិទ្ធិអំណាចរបស់ តា ម៉ុក។

# តួនាទីរបស់ អោ អាន ក្នុងភូមិភាគកណ្តាល

57. ពេលមួយនៅចន្លោះចុងខែ មករា និងចុងខែ កុម្ភៈ ឆ្នាំ ១៩៧៧ ក្រុមកម្មាភិបាលភូមិភាគនិរតីមួយក្រុមមានគ្នាប្រមាណ ១០០ ទៅ ៣០០ នាក់ រួមទាំង អោ អាន ផង ត្រូវបានផ្ទេរពីភូមិភាគនិរតីទៅ

ភូមិភាគកណ្តាល។ សមាជិកក្រុមនេះបានស្គាល់គ្នាយ៉ាងច្បាស់ ដោយបានធ្វើការជាមួយគ្នាយ៉ាងជិតស្និទ្ធនៅភូមិភាគនិរតី។ តា ម៉ុក បានជូនដំណឹងដោយផ្ទាល់ដល់កម្មាភិបាលមួយចំនួនអំពីការផ្ទេរដែលនឹងមកដល់របស់ពួកគេ ហើយលេខាធិការភូមិភាគកណ្តាល កែ ពក ត្រូវបានជូនដំណឹងអំពីការមកដល់ឆាប់ៗរបស់ពួកគេ តាមរយៈ “លិខិតបេសកកម្ម” មួយច្បាប់។ ក្រុមនេះត្រូវបាននាំទៅកាន់ភ្នំពេញដោយលេខាភូមិភាគនិរតី តា ម៉ុក និងបន្ទាប់មកបានប្រជុំគ្នានៅទីនោះដោយលេខាធិការភូមិភាគកណ្តាល កែ ពក ដែលបានដឹកនាំក្រុមនេះ ដោយផ្ទាល់ទៅកាន់ភូមិភាគកណ្តាល។

58. នៅពេលក្រុមកម្មាភិបាលភូមិភាគនិរតីបានមកដល់ភូមិភាគកណ្តាល កន្លែងដែលពួកគេឈប់ដំបូងគឺមន្ទីរភូមិភាគរបស់ កែ ពក ក្នុងទីរួមខេត្តកំពង់ចាម។ នៅទីនោះ ពួកគេបានជួបប្រជុំរយៈពេលពីរឬបីថ្ងៃ ដែលក្នុងពេលនោះ កែ ពក បានតែងតាំង **អោ អាន** ជាលេខាធិការតំបន់ ៤១ និងជាលេខាធិការតំបន់ ៤២ និង៤៣ ផងដែរ។ **អោ អាន** ក៏បានក្លាយទៅជាអនុលេខាធិការភូមិភាគកណ្តាលផងដែរ ដែលជាតំណែងមួយតម្រូវឲ្យគាត់បំពេញតួនាទីជំនួស កែ ពក នៅពេល កែ ពក អវត្តមាន។ គាត់ក៏បានក្លាយជាសមាជិកគណៈកម្មាធិការភូមិភាគកណ្តាលផងដែរ។

59. បន្ទាប់ពីកិច្ចប្រជុំគ្នាក្នុងទីរួមខេត្តកំពង់ចាម **អោ អាន** និងកម្មាភិបាលផ្សេងទៀតត្រូវបានដឹកទៅកាន់មន្ទីរតំបន់ ៤១ នៅព្រៃទទឹង ដោយរថយន្តដឹកទំនិញ ដែលជាកម្មសិទ្ធិរបស់ភូមិភាគនេះ។ នៅទីនោះ **អោ អាន** បានចាប់ផ្តើមប្រើអំណាចរបស់គាត់ជាលេខាធិការតំបន់ដោយតែងតាំងលេខាធិការស្រុកចំនួនប្រាំនាក់នៅក្នុងតំបន់ ៤១ ដែលបម្រើការជាអ្នកក្រោមបង្គាប់ផ្ទាល់របស់គាត់។

60. សេចក្តីថ្លែងការណ៍របស់ **អោ អាន** ទៅកាន់អ្នកក្រោមបង្គាប់របស់គាត់នៅក្នុងកិច្ចប្រជុំនោះ បានបន្ទរសេចក្តីណែនាំដែលគាត់ទទួលបានពី កែ ពក។ នៅក្នុងកិច្ចប្រជុំនានាក្នុងខេត្តកំពង់ចាម ដែល **អោ អាន** និងកម្មាភិបាលជាន់ខ្ពស់ដទៃទៀត មកពីតំបន់នានានៃភូមិភាគកណ្តាលបានចូលរួម កែ ពក បាននិយាយថា មានបញ្ជាពីថ្នាក់លើឲ្យធ្វើការបោសសម្អាត ដោយសង្កត់ធ្ងន់ថា កម្មាភិបាល “ត្រូវធ្វើយ៉ាងណាក៏ដោយឲ្យតែអាចចាប់ខ្លួនពួកខ្មាំងទាំងអស់នោះបាន” ហើយថា “នៅពេលដកស្មៅ” កម្មាភិបាលគួរតែ “ដកទាំងឫស”។ បន្ថែមពីលើការដាស់តឿនទូទៅទាំងនេះ **អោ អាន** ក៏បានទទួលបញ្ជាជាក់លាក់ជាលាយលក្ខណ៍អក្សរពី កែ ពក ឲ្យសម្លាប់មនុស្សផងដែរ។ **អោ អាន** ខ្លួនឯងបានសារភាពថា គាត់បានទទួលបញ្ជាពី កែ ពក ឲ្យសម្លាប់មនុស្ស និងបានសារភាពថា គាត់ក្រោយមកបានប្រាប់ កែ ពក ថា គាត់បានធ្វើតាមបញ្ជាទាំងនោះរួចហើយ។

## ការដាក់ អោ អាន ឲ្យស្ថិតក្រោមការពិនិត្យរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

61. នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ **Mark Harmon** បានចេញដីកាកោះហៅ អោ អាន ឱ្យចូលខ្លួនជាលើកដំបូង។ នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានធ្វើនីតិវិធីបង្ហាញខ្លួនលើកដំបូង និងជូនដំណឹងអំពីការចោទប្រកាន់ប្រឆាំងនឹង អោ អាន នូវបទល្មើសដូចខាងក្រោម៖

**ការរំលោភបំពានមាត្រា៥០១ និងមាត្រា៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦**

-មនុស្សឃាតដោយចេតនា ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៣ថ្មី និងមាត្រា ៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ**

-ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ឬសាសនា (លើកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជានៅភូមិភាគកណ្តាល អតីតមន្ត្រីសាធារណរដ្ឋខ្មែរ រួមទាំង មន្ត្រីស៊ីវិល និងយោធា ជនជាតិចាម និងគ្រួសាររបស់ពួកគេ)។

-ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងទៀត ដូចជា ស្ថានភាពអមនុស្សធម៌នៃការឃុំឃាំង។

ឧក្រិដ្ឋកម្មទាំងនេះមានចែង និងត្រូវផ្តន្ទាទោសតាមមាត្រា ៥ និងមាត្រា ៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។[49]

62. នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ **Mark Harmon** បានសុំលាលែងពីតំណែង ហើយត្រូវជំនួសវិញដោយលោក **Michael Bohlander** ។ បន្ទាប់មក លោក **Michael Bohlander** បានចេញដីកាកោះហៅ អោ អាន ដើម្បីឱ្យបង្ហាញខ្លួនម្តងទៀត[50]។

63. នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ គឺជាថ្ងៃកំណត់ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ **Michael Bohlander** ឱ្យ អោ អាន ចូលបង្ហាញខ្លួនម្តងទៀត ប៉ុន្តែ អោ អាន មិនបានចូលបង្ហាញខ្លួនតាមការកោះហៅនេះទេ គឺមានតែសហមេធាវីការពារក្តីចូលរួមតែប៉ុណ្ណោះ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានជូនដំណឹងទៅសហមេធាវីការពារក្តី អោ អាន អំពីការចោទប្រកាន់អំពីអំពើឧក្រិដ្ឋ

[49] **D242** កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥។

[50] ឯកសារ A497, ដីកាកោះឱ្យបង្ហាញខ្លួនម្តងទៀតរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៦ ដើម្បីកោះហៅ អោ អាន ឱ្យចូលបង្ហាញខ្លួនម្តងទៀតនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ វេលាម៉ោង ១០ព្រឹក។

ដែលសហព្រះរាជអាជ្ញាអន្តរជាតិស្នើឲ្យបើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋាន និងចម្លើយតបមួយចំនួនដូចខាងក្រោម៖

- ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨

- ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១

- ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាយេនឌ័រ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤

- ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទាក់ទងនឹងវត្តតាមះ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៥ និង

- ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ D237 ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៥។

64. តាមរយៈដីកាសន្និដ្ឋាន និងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិខាងលើនេះ គឺ អោ អាន ត្រូវបានសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចោទប្រកាន់ថាបានទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋទាំងនោះក្នុងនាមជាមេដឹកនាំជាន់ខ្ពស់ម្នាក់នៃរបបកម្ពុជាប្រជាធិបតេយ្យ ឬជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើឧក្រិដ្ឋទាំងនោះ។ ជាមួយគ្នានេះដែរ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានជូនដំណឹងការចោទប្រកាន់បន្ថែម ប្រឆាំងអោ អាន នូវបទល្មើសដូចខាងក្រោម៖

**-ការរំលោភលើមាត្រា ២០៩ ២១០ ៥០០ ៥០១ និង ៥០៣ ដល់ ៥០៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦** (មនុស្សឃាត ទារុណកម្ម និងការធ្វើទុក្ខបុកម្នេញលើសាសនា)

**-ការរំលោភលើអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឆ្នាំ១៩៤៨** (អំពើប្រល័យពូជសាសន៍)

**-ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** (ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ និងសាសនា និងអំពើអមនុស្សធម៌ដទៃទៀត) និង

**-អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩** (ការធ្វើមនុស្សឃាតដោយចេតនា ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព ការដកហូតសិទ្ធិ ឬការផ្លាស់ទីលំនៅ ឬការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់)។

បទល្មើសទាំងនេះមានចែង និងត្រូវផ្តន្ទាទោសតាមមាត្រា ៣ថ្មី, ៤, ៥, ៦, ២៩ និងមាត្រា ៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។[51]

65. បន្ទាប់ពីបានពិនិត្យពិចារណាលើភស្តុតាងដែលមាននៅក្នុងសំណុំរឿងរួចមក សហចៅក្រមចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចដាក់ អោ អាន ឲ្យស្ថិតក្រោមការពិនិត្យជាពិសេសដោយសារតំណែងពីមុនរបស់គាត់ជាអនុប្រធានភូមិភាគកណ្តាល(ឧត្តរចាស់), សមាជិកនៃគណៈភូមិភាគកណ្តាល(ឧត្តរចាស់), លេខាតំបន់ ៤១ ភូមិភាគកណ្តាល(ឧត្តរចាស់) ហើយបានដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទចោទដូចខាងក្រោម៖

- អំពើប្រល័យពូជសាសន៍ ដែលបានប្រព្រឹត្តឡើងនៅភូមិភាគកណ្តាលលើជនជាតិចាម នៅខេត្តកំពង់ចាម

- ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តឡើងជាផ្នែកមួយនៃការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធ ដែលសំដៅលើប្រជាជនស៊ីវិល ដោយមូលហេតុសញ្ជាតិនយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា។ ឧក្រិដ្ឋកម្មទាំងនេះបានប្រព្រឹត្តនៅការដ្ឋានធ្វើពលកម្មដោយបង្ខំនៅទំនប់អន្លង់ជ្រៃ, ទីកន្លែងសម្លាប់មនុស្សគោកព្រីង, មន្ទីរសន្តិសុខមិត្តសុប(គរ), មន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្សទួលបេង និងវត្តអង្គញជី, មន្ទីរសន្តិសុខវត្តអូរត្រកួន, មន្ទីរសន្តិសុខវត្តបាធាយ, ទីកន្លែងសម្លាប់មនុស្សវត្តភ្នំប្រុស, មន្ទីរសន្តិសុខវត្តតាមេះ, មន្ទីរសន្តិសុខចម្ការស្វាយចន្ទី, មន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក, មន្ទីរសន្តិសុខវត្តស្រម៉ៃ, អាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាលើផ្លូវភេទនៅស្រុកកំពង់សៀម និងស្រុកព្រៃឈរតំបន់៤១

- រំលោភលើមាត្រា ៥០១ និង ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលជាការប្រព្រឹត្តបទមនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅការដ្ឋានធ្វើពលកម្មដោយបង្ខំនៅទំនប់អន្លង់ជ្រៃ(សហចារី), ទីកន្លែងសម្លាប់មនុស្សគោកព្រីង(សហចារី), មន្ទីរសន្តិសុខមិត្តសុប (គរ)(សហចារី), មន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្សទួលបេង និងវត្តអង្គញជី

[51] **D303** កំណត់ហេតុនៃការបង្ហាញខ្លួនម្តងទៀត ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦។

(សហចារី ឬតាមរយៈការរៀបចំផែនការ ឬការបញ្ជា), មន្ទីរសន្តិសុខវត្តអូរត្រកួន (សហចារី ឬតាមរយៈការរៀបចំផែនការ ឬការបញ្ជា), មន្ទីរសន្តិសុខវត្តបាធាយ (សហចារី ឬតាមរយៈការរៀបចំផែនការ ឬការបញ្ជា), ទីកន្លែងសម្លាប់មនុស្សវត្តភ្នំប្រុស(សហចារី), មន្ទីរសន្តិសុខវត្តតាមេះ(សហចារី ឬតាមរយៈការរៀបចំផែនការ ឬការបញ្ជា), មន្ទីរសន្តិសុខចម្ការស្វាយចន្ទី(សហចារី), មន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក(សហចារី), មន្ទីរសន្តិសុខវត្តស្រង៉ែ(សហចារី) និង

- សហឧក្រិដ្ឋកម្មរួមដែលបានកើតឡើងប្រហែលចុងឆ្នាំ ១៩៧៦ យ៉ាងហោចណាស់រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ រួមជាមួយ កែ ពក, អោម អាន និងកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា(ប.ក.ក) ផ្សេងទៀតដែលបានចូលរួមក្នុងគោលបំណងរួមក្នុងការអនុវត្តគោលនយោបាយរបស់ប.ក.ក នៅភូមិភាគកណ្តាលនៃកម្ពុជាប្រជាធិបតេយ្យ និងតាមរយៈការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក រួមមាន ការបង្កើត និងដំណើរការសហករណ៍ និងការដ្ឋាន, ការកសាងសមាសភាពមិនល្អ និងការសម្លាប់ខ្មាំងទាំងនៅក្នុងជួរ ប.ក.ក ទាំងនៅក្រៅជួរ ប.ក.ក, ការដាក់មុខសញ្ញាលើក្រុមជាក់លាក់នានា ដូចជាកម្មាភិបាល ប.ក.ក នៅភូមិភាគកណ្តាល អតីតមន្ត្រីសាធារណរដ្ឋខ្មែរ ជនជាតិចាម និងក្រុមគ្រួសាររបស់ពួកគេ, និងការដាក់បទបញ្ជាលើអាពាហ៍ពិពាហ៍ តាមរយៈជាអាទិ៍ការរៀបអាពាហ៍ពិពាហ៍ឲ្យអ្នកនៅភូមិភាគកណ្តាលដោយបង្ខំ។

66. នៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញសេចក្តីជូនដំណឹងយោងតាមវិធានផ្ទៃក្នុង ៦៦ស្ទួន(២) ដោយបានបញ្ជាក់អំពីគោលបំណងក្នុងការកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ[52]។

67. នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ[53] ដោយដកចេញនូវអង្គហេតុដែលបានចោទប្រកាន់មួយចំនួនដូចខាងក្រោម៖

[52] ឯកសារ **D307/4** សេចក្តីជូនដំណឹងយោងតាមវិធានផ្ទៃក្នុង ៦៦ស្ទួន(២) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៦។

[53] ឯកសារ **D337** ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃក្នុង ៦៦ស្ទួន ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦។

- ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនៅតំបន់៤២ និង ៤៣ (មន្ទីរសន្តិសុខទួលតាផ្លុង, មន្ទីរសន្តិសុខវត្តកណ្តាល, មន្ទីរសន្តិសុខចម្ការស្វាយចន្ទី, មន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក, មន្ទីរសន្តិសុខវត្តស្រង៉ែ)
- ការចាប់ខ្លួន និងការសម្លាប់ជនជាតិចាមនៅភូមិភាគបូព៌ា
- ការធ្វើទារុណកម្មនៅទួលបេង/វត្តអង្គញដី
- ការដាក់ក្នុងមន្ទីរឃុំឃាំង និងការធ្វើទុក្ខបុកម្នេញនៅវត្តភ្នំប្រុស។

## ការយល់ឃើញរបស់សហព្រះរាជអាជ្ញាជាតិ

## ការរួចផុតពីការទទួលខុសត្រូវ

68. គោលនយោបាយបោសសម្អាត ត្រូវបានស្តែងឡើងតាមរយៈសេចក្តីសម្រេចរបស់គណៈមជ្ឈិមបក្ស ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ដែលពាក់ព័ន្ធនឹងសិទ្ធិសម្រេចកម្ទេចក្នុងជួរ និងក្រៅជួរ។ សាក្សីឈ្មោះ បាន សៀក ជាអតីតអនុលេខាស្រុកចំការលើ និងជាអតីតលេខាស្រុកក្រូចឆ្មារ បានផ្តល់សក្ខីកម្មថា "ភូមិភាគគ្រប់គ្រងដោយ កែ ពក ជាលេខាភូមិភាគ។ កែ ពក ជាប្រធានគណៈអចិន្ត្រៃយ៍ភូមិភាគ...តាមតែខ្ញុំដឹង ការសម្រេចសំខាន់ៗ ដូចជា ការបោសសម្អាតជាដើម ត្រូវបានសម្រេចដោយគណៈអចិន្ត្រៃយ៍ភូមិភាគ។"[54]

69. ខ្លឹមសារនៃសេចក្តីសម្រេចដដែលនេះ ក៏បានកំណត់ច្បាស់ផងដែរទាក់ទងនឹងការបោសសម្អាតនៅក្នុងភូមិភាគ គឺក្នុងក្របខណ្ឌមូលដ្ឋាន ត្រូវ "**អចិន្ត្រៃយ៍ភាគសម្រេច**"។[55] ដូចដែល ឌុច បានរៀបរាប់ពាក់ព័ន្ធនឹងខ្លឹមសារនៃសេចក្តីសម្រេចនេះថា "ឯកសារនេះមានលក្ខណៈជាប្រវត្តិសាស្ត្របញ្ជាក់ពីរបត់មួយនៃការចាប់ផ្តើមការសម្រិតសម្រាំងផ្ទៃក្នុងបក្ស។"[56]

[54] **D107/15** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីឈ្មោះ បាន សៀក ឈ្មោះហៅក្រៅ ហង្ស ផុស ហៅ ហង្ស ស៊ុនហូ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១២ ទំព័រ៣។

[55] **D1/3/19/1** ឯកសារស្តីពីសេចក្តីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ទំព័រ១។ **D6/1/1073** ឯកសារនៃការដាក់ចម្លើយរបស់ជនត្រូវចោទឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច ជាអតីតប្រធានមន្ទីរសន្តិសុខ ស-២១ ដែលបានធ្វើការឆ្លើយតបទៅនឹងសំណួរជាលាយលក្ខណ៍អក្សររបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨ ទំព័រ៣។ **D6/1/91** កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៨ ទំព័រ៣។ **D6/1/1060** កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៨ ទំព័រ១៥។

[56] **D6/1/1063** កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៨ ទំព័រ៧។

70. ក្នុងនាមជាលេខាភូមិភាគ កែ ពក តែងតែធ្វើការដឹកនាំការប្រជុំជានិច្ច អំពីរបៀបចាប់ខ្លួនខ្មាំង ដល់អ្នកនៅក្រោមបង្គាប់ ដើម្បីសម្រេចតាមផែនការរបស់បក្សកុំម្មុយនីស្តកម្ពុជា ស្របតាមសក្ខីកម្មរបស់ ញ៉ែម អេន ដែលបានបញ្ជាក់ថា "កែ ពក និយាយដែរអំពីខ្មាំង ក្នុងរយៈពេលហ្នឹងឲ្យចុះតាមស្រុក ចាត់ផែនការហ្នឹងទៅស្រុក ទៅដល់អត់ឲ្យឈប់ទេ ចុះតាមស្រុកចាប់ឲ្យរហ័ស ព្រោះផែនការគេជិតដល់ហើយ។"[57]

71. សក្ខីកម្មរបស់ ប្រាក់ យុត ហៅ យាយ យុត អតីតលេខាស្រុកកំពង់សៀម ចំនួន១០លើក។[58] ដំបូង ប្រាក់ យុត ម្តងគាត់បានឆ្លើយថាមិនស្គាល់ អោ អាន ទេ ហើយក្រោយមកទៀត បានឆ្លើយថា ស្គាល់ អោ អាន ដោយសារធ្លាប់ធ្វើការនៅក្នុងភូមិភាគនិរតី និងបានផ្ទេរមកភូមិភាគកណ្តាលជាមួយគ្នា។ ចំណែកឯ កែ ពេជ្រវណ្ណៈ មិនបានឆ្លើយដាក់បន្ទុក កែ ពក ដែលជាឪពុករបស់ខ្លួន ហើយក៏មិនបានឆ្លើយដាក់បន្ទុក អោ អាន ដែរ ប៉ុន្តែផ្ទុយទៅវិញមានសាក្សីជាច្រើន ដូចជា វង សុគន្ធ, សា ណូ បានបញ្ជាក់ថា ធ្លាប់បានឃើញ កែ ពក ឈរបញ្ជាឲ្យសម្លាប់មនុស្ស។[59]

[57] **D219/855** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ទំព័រ៦។

[58] **D6/1/730** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ ប្រាក់ យុត ហៅ យាយ យុត (លើកទី១) ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ១-១២។ **D6/1/733** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ ប្រាក់ យុត ហៅ យាយ យុត (លើកទី២) ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ១-៣។ **D6/1/721** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ ប្រាក់ យុត ហៅ យាយ យុត (លើកទី៣) ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ទំព័រ១-៨។ **D6/1/722** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ ប្រាក់ យុត ហៅ យាយ យុត (លើកទី៤) ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៩ ទំព័រ១-៧។ **D117/70** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ ប្រាក់ យុត ហៅ យាយ យុត (លើកទី៥) ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៣ ទំព័រ១-៩។ **D117/71** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ ប្រាក់ យុត ហៅ យាយ យុត (លើកទី៦) ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ទំព័រ១-១២។ **D117/72** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ ប្រាក់ យុត ហៅ យាយ យុត (លើកទី៧) ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣ ទំព័រ១-៤។ **D117/73** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ ប្រាក់ យុត ហៅ យាយ យុត (លើកទី៨) ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៣ ទំព័រ១-៦។ **D219/120** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ ប្រាក់ យុត ហៅ យាយ យុត (លើកទី៩) ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤ ទំព័រ១-១៩។ **D219/484** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ ប្រាក់ យុត ហៅ យាយ យុត (លើកទី១០) ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៥ ទំព័រ១-៨។

[59] **D3/19** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ វង សុគន្ធ ឈ្មោះហៅក្រៅ អាគន្ធ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១០ ទំព័រ៥។ **D107/19/1** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ វង សុគន្ធ ឈ្មោះហៅក្រៅ អាគន្ធ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២ ទំព័រ៤-៥។ **D3/10** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ នីវ ស៊ុន ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១០ ទំព័រ៤។ **D107/5** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ អ៊ិន គីមអេង ឈ្មោះហៅក្រៅ ថេង ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១២ ទំព័រ៣-៤។ **D107/19/1** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ វង សុគន្ធ ឈ្មោះហៅក្រៅ អាគន្ធ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២ ទំព័រ៤-៥។ **D6/1/111** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ សា ណូ ឈ្មោះហៅក្រៅ សា ម៉ាត់ណូ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៨ ទំព័រ៣។

72. មានសាក្សីខ្លះបានឆ្លើយថា កែ ពក បានគ្រប់គ្រងយ៉ាងតឹងរ៉ឹង ចេញបញ្ជារាល់ការងារទាំងអស់ក្នុងភូមិភាគ។ ការងារទាំងអស់តម្រូវអោយរាយការណ៍ និងឆ្លងយោបល់ដើម្បីទទួលបញ្ជាពី កែ ពក[60] រួមទាំងសិទ្ធិអំណាចក្នុងការដឹកនាំកិច្ចប្រជុំភូមិភាគ។ មានសាក្សីជាច្រើនបានអះអាងថា តា អាន មានតែតំណែងជា អនុភូមិភាគប៉ុណ្ណោះ ប៉ុន្តែជាក់ស្តែង គាត់មិនមានអំណាចក្នុងការសម្រេចទេ ដោយសារសេចក្តីសម្រេចក្នុងភូមិភាគគឺធ្វើឡើងដោយ កែ ពក ក្រោយពីបានទាក់ទង និងទទួលការណែនាំនានា ជាអាទិ៍តាមរយៈទូរលេខដែល កែ ពក បានបញ្ជូនទៅ និងទទួលពីមន្ទីរ ៨៧០។

73. ការមកដល់របស់ អោ អាន ក្នុងភូមិភាគកណ្តាល ស្របពេលមានសេចក្តីថ្លែងការណ៍របស់ ខៀវ សំផន ហៅ ហែម ជាគណៈប្រធានរដ្ឋ ពាក់ព័ន្ធនឹងបទបញ្ជាឲ្យឈប់សម្លាប់។ ការស្លាប់ នៅតែមានបន្ត ដោយសារពេលនោះ កម្ពុជាប្រជាធិបតេយ្យ បានជួបប្រទះទុរ្ភិក្សការអត់ឃ្លានពេញផ្ទៃប្រទេស ដែលបណ្តាលមកពីផលវិបាកនៃការអនុវត្តគោលនយោបាយ ដាក់ចេញដោយអង្គការថ្នាក់លើតម្រូវឲ្យប្រជាជននៅតាមមូលដ្ឋានត្រូវធ្វើស្រូវឲ្យបាន "**បីតោនក្នុងមួយហិកតា**"។ ការណ៍នេះ បានបណ្តាលឲ្យប្រជាជនទូទាំងប្រទេស ស្លាប់ដោយសារអត់អាហារ និងជម្ងឺ និងកង្វះខាតថ្នាំព្យាបាលជម្ងឺ ជាពិសេស តំបន់៤១ ក្នុងភូមិភាគកណ្តាល ដែល អោ អាន ជាលេខាតំបន់។

74. ជាក់ស្តែង សាក្សីឈ្មោះ វី ញ៉ូ បានបញ្ជាក់ថា "មុនគេចាប់ផ្តើមបញ្ជូនពួកនិរតីមកគេហៅពួកអ្នកនៅកំពង់ចាមឲ្យទៅរៀនសូត្រ រួមមាន ប្រធានតំបន់ លេខាស្រុកអីទាំងអស់ រួមមាន ផាន់ ផង។ ទៅរៀនហើយបាត់ទាំងអស់ទៅ មិនឃើញត្រឡប់មកវិញទេ។ បន្ទាប់មកបានឃើញពួកនិរតីមក"។[61] សាក្សីឈ្មោះ សំរិទ្ធិ អន អះអាងដូចគ្នានេះដែរថា "ពេលមិត្តសឹមហ្នឹងសម្លាប់មុនពួកនិរតីចូលមកដល់"។[62] សាក្សីឈ្មោះ ញ៉ែម ចេន អតីតកងការពារ អោ អាន បាននិយាយថា "ចាប់មុនពេល អោ អាន មកដល់...គេចាប់អស់ហើយបាន តា អាន មកដល់នៅតែមេកងមេអី"។[63] អោ អាន ក៏បានលើកឡើងត្រង់ចំណុចនេះដែរថា "អស់អាលីញអាលត់ហើយនៅតែ កែ ពក មួយទេ"។[64]

---

[60] **D6/1/697** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ សួន កានិល ឈ្មោះបដិវត្តហៅ នាង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២00៩ ទំព័រ៦។

[61] **D219/870** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ វី ញ៉ូ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ ទំព័រ៤។

[62] **D219/609** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ សំរិទ្ធ អន ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ ទំព័រ៤។

[63] **D219/855** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ទំព័រ៥។

[64] **D191/2** ឯកសារនៃកិច្ចសម្ភាសន៍ជាមួយ អោ អាន ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១ ដោយលោក ឡុង ដានី និងលោក វ៉ាន់ថាន់ ពៅដារ៉ា ទំព័រ៣៨។ **D117/62** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ គង់ យឿន ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៤ ទំព័រ៣។ **D117/35** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ បាន សៀក ឈ្មោះហៅ ក្រៅ ហង្ស ផុស ហៅ ហង្ស ស៊ុនហូ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៤ ទំព័រ៨។ **D219/138** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សី

75. អោ អាន បានកាន់តំណែងជាលេខាតំបន់៤១ អស់រយៈពេលជាងមួយឆ្នាំ ហើយក្រោយមកកាន់តំណែងជាលេខាភូមិភាគកណ្តាលនេះ បានមួយរយៈពេលខ្លី មុនពេលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំនៅឆ្នាំ១៩៧៩។ មានសាក្សីជាច្រើនបានឆ្លើយថា ពួកគេមិនបានស្គាល់ អោ អាន ហើយមិនបានដឹងការចូលរួម និងការទទួលខុសត្រូវរបស់ អោ អាន ទេ ខណៈដែលមានសាក្សីខ្លះទៀត បានអះអាងថា អោ អាន គ្រាន់តែជាអ្នកទទួលបញ្ជាពីថ្នាក់លើ ដែលសំដៅទៅលើ កែ ពក ឬគណៈកម្មាធិការមជ្ឈិមបក្ស ដែលជាអ្នកដាក់ចេញនូវបញ្ជា។

76. ពុំមានភស្តុតាងណាមួយដែលបញ្ជាក់ថា អោ អាន ទទួលការងារគ្រប់គ្រងជំនួស កែ ពក ក្នុងនាមជាលេខាភូមិភាគស្តីទីម្តងណាឡើយ ពេល កែ ពក អវត្តមាន។ មានសាក្សីជាច្រើនបានផ្តល់សក្ខីកម្មថា មិនធ្លាប់ឃើញ អោ អាន មានវត្តមាននៅមន្ទីរភូមិភាគកណ្តាល ជំនួសការងារ កែ ពក ឡើយ ក្រៅពីឃើញ អោ អាន មានវត្តមាននៅពេលចូលរួមប្រជុំនៅភូមិភាគ។

77. សាក្សី សួន កានិល ដែលជាអតីតប្រធានក្រុមសារទូរលេខនៅមន្ទីគណៈភូមិភាគកណ្តាល បានអះអាងថា "តាមខ្ញុំដឹង កែ ពក មិនដែលចេញទៅណាទេ ក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ។ គាត់អវត្តមានតែនៅពេលដែលគាត់ទៅសមរភូមិ ទៅប្រជុំនៅភ្នំពេញ ឬចុះមើលការដ្ឋានទំនប់

ឈ្មោះ យូ វ៉ាន់ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ទំព័រ១២។ **D219/541** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ គឹម គឿន ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ ទំព័រ៤ (ឆ.១៦)។

ប្រឡាយមួយរយៈប៉ុណ្ណោះ"។[65] សាក្សីរូបនេះ បានបន្តទៀតថា "ក្នុងករណី កែ ពក អវត្តមាន គឺមានគេមកជួបប្រធានមន្ទីរគណៈភូមិភាគ ឈ្មោះ ស៊ូ"។[66]

78. តាមការដឹកនាំតាមបែបកុម្មុយនីស្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានផ្តល់អំណាចឲ្យបក្សជាអ្នកមានអំណាចខ្ពស់បំផុត ពោលគឺ គណៈកម្មាធិការមជ្ឈិមបក្ស ដែលជាថ្នាក់ដឹកនាំកំពូលរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវធ្វើការសម្រេចលើការងារសំខាន់ៗពាក់ព័ន្ធនឹងជោគវាសនាប្រទេសជាតិ។គណៈកម្មាធិការនេះមានសមាសភាពប្រហែល ៣០រូប មានការប្រជុំជាទៀងទាត់(៦ខែម្តង)។ ការអនុវត្តជាក់ស្តែង សមាសភាពដែលត្រូវចូលរួមប្រជុំក៏មានការចូលរួមពីថ្នាក់ដឹកនាំគណៈភូមិភាគ និងគណៈតំបន់ផងដែរ។ ជាក់ស្តែង អំណាចលើការសម្រេចនានាគឺស្ថិតនៅលើ គណៈកម្មាធិការអចិន្ត្រៃយ៍បក្សជាអ្នកសម្រេច ហើយដើរតួនាទីដ៏សំខាន់ក្នុងការដឹកនាំការងារប្រចាំថ្ងៃជំនួសគណៈកម្មាធិការមជ្ឈិមបក្ស។ គណៈកម្មាធិការនេះមានសមាសភាពចំនួន ៧រូប ដែលក្នុងនោះ ប៉ុល ពត គឺជាលេខាបក្ស និង នួន ជា គឺជាអនុលេខាបក្ស។

79. បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានបង្កើតឡើងតាំងពីមុនការកាន់អំណាចនៃរបបកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ១៩៧៥ ដល់ ១៩៧៩ មកម្ល៉េះ។ របបកម្ពុជាធិបតេយ្យ ដឹកនាំតាមបែបកុម្មុយនីស្តដោយមានបក្សជាអ្នកដឹកនាំគ្រប់អ្វីៗទាំងអស់។ គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា មានគោលដៅ

[65] **D29** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ សួន កានិល ឈ្មោះបដិវត្តហៅ នាង ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១ ទំព័រ៤។ **D219/178** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ គុច វ៉ា ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៥ ទំព័រ៥។ **D6/1/4** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ អឿន តាន ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៨ ទំព័រ៤។ **D117/26** កំណត់ហេតុនៃស្តាប់ ចម្លើយ សាក្សីឈ្មោះ ពុត កុល ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣ ទំព័រ៥។ **D191/2** ឯកសារនៃកិច្ចសម្ភាសន៍ជាមួយ អោ អាន ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១ ដោយលោក ឡុង ដានី និងលោក វ៉ាន់ថាន់ ពៅដារ៉ា ទំព័រ៤៤។ **D29** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ សួន កានិល ឈ្មោះបដិវត្តហៅ នាង ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១ ទំព័រ៤។ **D74** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ វ័ន្ន ពៅ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១១ ទំព័រ៣។ **D6/1/379** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ កែវ ពេជ្រវណ្ណៈ ឈ្មោះបដិវត្តហៅ វណ្ណៈ, ថា, យុទ្ធ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ៥ និងទំព័រ១៤។ **D78** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ ជិន ស៊ីណាល់ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១១ ទំព័រ៤។ **D6/1/1070** កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៨ ទំព័រ៧។ **D6/1/1085** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ ថា សុត ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៨ ទំព័រ៤។ **D6/1/1076** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ សៅ សារុន ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៧ ទំព័រ២-៣។ **D1/3/27/5** ឯកសារបទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ រៀបចំសម្រាប់គណៈកម្មាធិការ Ishiyama របាយការណ៍ប្រចាំឆ្នាំ១៩៨០ ខែកុម្ភៈ-មីនា ឆ្នាំ២០០៨ ទំព័រ២២។ **D6/1/475** កំណត់ហេតុនៃស្តាប់យកចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ អាហ្វុងកូ ដឺណីស (Mrs. AFFONCO Denise) ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ១៧។

[66] **D6/1/707** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សីឈ្មោះ សួន កានិល ឈ្មោះបដិវត្តហៅ នាង ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩ ទំព័រ៣។

ធ្វើការបោសសម្អាត វណ្ណៈសក្តិភូមិ នាយទុន និងបញ្ញាវន្ត ជាអាទិ៍ ហើយបានចាត់ទុកអ្នកទាំងនេះជាខ្មាំងដែលគេចោទថាធ្លាប់កេងប្រវ័ញ្ច និងជិះជាន់លើប្រជាជននាពេលកន្លងមក។ ដូច្នេះហើយទើបបក្សកុម្មុយនីស្តកម្ពុជា បានដាក់ចេញនូវគោលនយោបាយជាការសងសឹកចំពោះអ្នកទាំងនោះ។

80. នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក៏មានគោលនយោបាយបង្ក្រាប ដែលតម្រូវឲ្យកម្មាភិបាលនៃរបបនេះត្រូវតែអនុវត្តតាម បើមិនដូច្នោះទេកម្មាភិបាលដែលប្រឆាំងនឹងគោលនយោបាយត្រូវរងការបោះសម្អាត។ ការបង្ក្រាបនេះបានចាប់ផ្តើមពីការចាប់ខ្លួនបណ្តាមេដឹកនាំភូមិភាគមួយចំនួនយកទៅសម្លាប់នៅមន្ទីរសន្តិសុខ ស-២១ ដូចជា កុយ ធួន, សោ ភឹម, វន វ៉េត, វស់ ញឹម, កង ចាប ហៅ សែ ជាដើម។

81. ការបង្ក្រាបកាន់តែរាលដាល លាតសន្ធឹងទូទាំងប្រទេស ជាពិសេសក្នុងឆ្នាំ១៩៧៦ ក្រោយពីមានសេចក្តីសម្រេចរបស់គណៈកម្មាធិការមជ្ឈិមបក្ស ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៧៦ ហើយស្របពេលដែលពាក្យ "ខ្មាំង" ត្រូវបានពង្រីកន័យ និងប្រើយ៉ាងទូលំទូលាយ។ បើសិនជានរណាម្នាក់ត្រូវបានចោទថាជាខ្មាំង អ្នកនោះនឹងត្រូវយកទៅសម្លាប់ចោលដោយគ្មានរកខុសត្រូវ និងឆ្លងកាត់នីតិវិធីតុលាការឡើយ។

82. ដូចបានលើកឡើងខាងលើរួចហើយ តួនាទី អោ អាន មិនមានការតែងតាំងជាផ្លូវការណាឡើយ ហើយការចូលរួមសកម្មភាពការងារផ្សេងៗគឺធ្វើឡើងតាមបញ្ជា និងការណែនាំរបស់ថ្នាក់លើ ជាពិសេស កែ ពក ដែលស្ថិតនៅគ្រប់គ្រងដឹកនាំភូមិភាគកណ្តាលជាប្រចាំ។ សាក្សីឈ្មោះ ញ៉ែម ចេន បាននិយាយថា កែ ពក ទទួលបញ្ជាពី ប៉ុល ពត ហើយ តា អាន ទទួលបញ្ជាពី កែ ពក។ កែ ពក ជាមនុស្សមានអំណាចឥទ្ធិពល និងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយ សមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា។ អតីតប្រធានមន្ទីរសន្តិសុខ ស-២១ កាំង ហ្កេកអ៊ាវ ហៅ ឌុច បាននិយាយថា កែ ពក ជួនកាលក៏ត្រូវបានកោះអញ្ជើញឲ្យចូលរួមកិច្ចប្រជុំរបស់ គណៈកម្មាធិការអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តដែរ។ ឌុច ក៏បាននិយាយទៀតដែរថា មានថ្ងៃមួយមានមនុស្សម្នាក់ ដែលមកពីភូមិភាគ កណ្តាល បាននិយាយនៅក្នុងចម្លើយសារភាពរបស់គាត់ថា កែ ពក បានក្បត់ដោយស្តុកអាវុធនៅខេត្តកំពង់ចាមនៅវត្តដីដុះ ហើយ ឌុច បានរាយការណ៍ទៅ នួន ជា ហើយគាត់(នួន ជា) បានឆ្លើយថា កែ ពក មិនក្បត់ទេ។ លើសពីនេះទៀត ឌុច ក៏បាននិយាយដែរថា មានពេលមួយនោះ កុយ ធួន បានឆ្លើយដាក់ កែ ពក ប៉ុន្តែ សុន សេន បានសម្រេចឲ្យ កុយ ធួន ឆ្លើយគេចពី កែ ពក សិន។ លុះក្រោយមកទៀត នៅពេលដែល សុន សេន អនុញ្ញាតឲ្យឆ្លើយដាក់ កែ

ពក ប៉ុន្តែពេលចប់ចម្លើយ សុន សេន ប្រាប់ឲ្យខាង ស-២១ លុបគ្រប់កន្លែងដែលមានឈ្មោះ កែ ពក ចេញវិញ។[67]

83. ការលើកឡើងខាងលើនេះបង្ហាញឲ្យឃើញថា អោ អាន មិនមានស្វ័យភាព និងអំណាចជាក់ស្តែងទេ ស្ថិតនៅក្រោមបង្គាប់របស់ កែ ពក។ អោ អាន មិនអាចធ្វើការទាក់ទងជាមួយអង្គការថ្នាក់ខ្ពស់បានទេ។ លើសពីនេះទៀត គោលនយោបាយ និងផែនការដែលត្រូវដាក់ឲ្យអនុវត្ត គឺត្រូវបានរៀបចំដោយថ្នាក់លើជាន់ខ្ពស់ ហើយបានធ្វើការផ្សព្វផ្សាយយ៉ាងទូលំទូលាយដល់គ្រប់ទីកន្លែងបន្តដល់ថ្នាក់ក្រោមតាមរយៈកិច្ចប្រជុំផ្សព្វផ្សាយ។ ផែនការ និងទិសដៅការងារ ត្រូវតែបានអនុវត្តដោយកម្មាភិបាលតាមតួនាទីដោយគ្មានការវេញវោល។ ករណីមានការតវ៉ា ឬមិនបានបំពេញតាម ឬធ្វើខុសនឹងវិន័យអង្គការ កម្មាភិបាលគ្រប់ជាន់ថ្នាក់ទាំងអស់នឹងត្រូវលត់ដំ និងក្នុងករណីខ្លះត្រូវបានចាប់យកទៅសម្លាប់ចោល។ ករណីនេះ អោ អាន ធ្លាប់បានអះអាងដែរថា ភាពដាច់ខាតដែលគាត់ត្រូវគោរព និងការភ័យខ្លាចដល់ជីវិតប្រសិនបើគាត់មិនគោរពតាម។

## ការមិនអាចអនុវត្តយុត្តាធិការបុគ្គល

84. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានអាណត្តិ មានន័យថាមិនមែនជាតុលាការអចិន្ត្រៃយ៍ទេ។ អង្គជំនុំជម្រះនេះ មានលំនាំដូចជា តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) តុលាការឧក្រិដ្ឋកម្មអន្តរជាតិរ៉្វាន់ដា (ICTR) និងតុលាការពិសេសសម្រាប់សេរ៉ាឡេអូន (SCSL) ដែលបច្ចុប្បន្ន តុលាការឧក្រិដ្ឋកម្មអន្តរជាតិរ៉្វាន់ដា (ICTR) និងតុលាការពិសេសសម្រាប់សេរ៉ាឡេអូន (SCSL) បានបញ្ចប់អាណត្តិរបស់ខ្លួនជាបណ្តើរៗហើយ។

85. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានបង្កើតឡើង ដោយកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយនឹងអង្គការសហប្រជាជាតិ និងច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោស **មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ** និង**ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត**ចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ៦ មករា ១៩៧៩។

[67] ឯកសារ **D359** កថាខណ្ឌទី២០៦, ២០៧,៥១១, ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន របស់សហចៅក្រមស៊ើបអង្កេតជាតិចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

86. រាជរដ្ឋាភិបាលកម្ពុជា ក្នុងនាមជាស្ថាបនិកមួយនៃកិច្ចព្រមព្រៀង អាចមានឥទ្ធិពលលើដំណើរការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងការបញ្ចប់អាណត្តិរបស់អង្គជំនុំជម្រះនេះ។ វិធីសាស្ត្រដែលអាចទទួលយកបានសម្រាប់ការបញ្ចប់អាណត្តិរបស់អង្គជំនុំជម្រះនេះ គឺការកម្រិតវិសាលភាពយុត្តាធិការបុគ្គល។ វិធីសាស្ត្របែបនេះ ត្រូវបានអនុវត្តនៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិរ៉្វាន់ដា (ICTR) និងតុលាការពិសេសសម្រាប់សេរ៉ាឡេអូន (SCSL)។

87. ចំពោះស្ថានភាពជាក់ស្តែង នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិដែលជាស្ថាបនិករបស់តុលាការនេះ តាមរយៈវិធាន និងលិខិតុបករណ៍ជាច្រើន បានណែនាំឲ្យតុលាការនេះ ផ្តោតតែទៅលើមេដឹកនាំជាន់ខ្ពស់ដែលសង្ស័យជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម នៅក្រោមយុត្តាធិការរបស់ខ្លួន[68]។ សេចក្តីសម្រេចលេខ៖២00៤ និងលេខ៖១៥0៣ របស់ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ បានអំពាវនាវតុលាការនិមួយៗ ធានាថា ក្នុងការពិនិត្យ និងបញ្ជាក់គាំទ្រលើការចោទប្រកាន់ថ្មី ដីកាចោទប្រកាន់ថ្មីនេះ ផ្តោតតែទៅលើមេដឹកនាំជាន់ខ្ពស់ ដែលសង្ស័យជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលឋិតនៅក្រោមយុត្តាធិការរបស់តុលាការពាក់ព័ន្ធ[69]។

88. ពាក់ព័ន្ធនឹងការកំណត់យុត្តាធិការបុគ្គល ចៅក្រមតុលាការ ICTY បានបង្កើតវិធានថ្មីៗជាច្រើន ដោយគោរពទៅតាមការណែនាំរបស់ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ ដូចជា វិធាន១១ស្ទួន និងវិធាន២៨ក នៃវិធានស្តីពីភស្តុតាង និងនីតិវិធីរបស់តុលាការ ICTY។ ចៅក្រមមិនបារម្ភទេថា ការបង្កើតវិធាននេះ រំលោភលក្ខន្តិកៈរបស់តុលាការ និងកម្រិតឯករាជ្យភាពរបស់រដ្ឋអាជ្ញា។ ចាប់តាំងពីការបង្កើតវិធាននេះមក តុលាការ ICTY បានបង្វែរសំណុំរឿងទៅតុលាការ

[68] សេចក្តីប្រកាសព័ត៌មាន "ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិអនុម័តយកវិធីសាស្ត្របង្វែរទៅតុលាការថ្នាក់ជាតិនូវករណីជាក់លាក់មួយចំនួនពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅអតីតយូហ្គោស្លាវី, UNSC ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២00១, សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិលេខ១៥0៣ ថ្ងៃទី២៨ ខែសីហា ឆ្នាំ២00៣ កថាខណ្ឌ៦-៧, សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិលេខ១៥៣៤ ថ្ងៃទី២៦ ខែមិនា ឆ្នាំ២00៤ កថាខណ្ឌ៥, សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិលេខ១៩៦៦ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២0១0"។

[69] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិលេខ១៥៣៤, ដូចជើងទំព័រ ២៥ ខាងលើ កថាខណ្ឌ៥។

ថ្នាក់ជាតិ ដោយអនុវត្តស្របតាមការណែនាំរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ក្នុងការប្រើវិធីសាស្ត្រពាក់ព័ន្ធនឹងការបិទតុលាការ[70]។

89. ចំពោះយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ មិនបានព្រមព្រៀងគ្នាផ្តល់យុត្តាធិការទៅតុលាការជាតិកម្ពុជា ក្នុងការជំនុំជម្រះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ដោយមនុស្សដែលស្ថិតនៅក្នុងប្រភេទ "**មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ**" និង "**ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត**" ចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ៦ មករា ១៩៧៩ ឡើយ។

90. ចំណុចនេះបង្ហាញថា ស្ថាបនិកតុលាការអន្តរជាតិ អាចមានឥទ្ធិពលលើវិសាលភាពយុត្តាធិការបុគ្គល និងកិច្ចការរបស់តុលាការ ដោយមិនធ្វើឲ្យប៉ះពាល់ដល់អនាគតិ និងឯករាជ្យភាពរបស់តុលាការឡើយ។ ការកម្រិតយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក គឺរាជរដ្ឋាភិបាលកម្ពុជាកំពុងតែដើរតួដូចក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដែលក្រុមប្រឹក្សានេះបានអនុវត្តចំពោះតុលាការ ICTY ICTRនិង SCSL អញ្ចឹងដែរ។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាជាតិជម្រុញឲ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងអង្គជំនុំជម្រះ ឲ្យធ្វើសកម្មភាពស្របតាមការកំណត់របស់រាជរដ្ឋាភិបាលកម្ពុជា និងតាមស្មារតីច្បាប់ អ.វ.ត.ក ដែលបានកំណត់យកតែ **មេដឹកនាំជាន់ខ្ពស់** និង**អ្នកទទួលខុសត្រូវខ្ពស់បំផុត** នៃរបបកម្ពុជាប្រជាធិបតេយ្យតែប៉ុណ្ណោះ មកស៊ើបសួរ និងជំនុំជម្រះ។

91. គោលគំនិតរបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងកិច្ចព្រមព្រៀងស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានសម្រិតសម្រាំង "**មេដឹកនាំជាន់ខ្ពស់**" តែមួយចំនួនតូចប៉ុណ្ណោះ ដែលស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ពោលគឺចង់សំដៅតែទៅលើសមាជិកនៃគណៈកម្មាធិការមជ្ឈិមបក្ស និងសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស រួមមាន ប៉ុល ពត, នួន ជា, សុន សេន,

[70]ករណីរឿងក្តី *Stankovic* (IT-96-23/2-PT), RB សេចក្តីសម្រេចស្តីពីការបង្វិលសំណុំរឿង អនុលោមតាមវិធាន១១ស្ទួន ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២00៥ កថាខណ្ឌ៩៦។ ករណីរឿងក្តី *D.Milosevic* (IT-98-29/1-PT), RB សេចក្តីសម្រេចស្តីពីការ បង្វិលសំណុំរឿង អនុលោមតាមវិធាន១១ស្ទួន ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២00៥ កថាខណ្ឌ២៤។ ករណីរឿងក្តី *Lukic & Lukic* (IT-98-23/1-PT), RB សេចក្តីសម្រេចស្តីពីការបង្វិលសំណុំរឿង អនុលោមតាមវិធាន១១ស្ទួន ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២00៧ កថាខណ្ឌ១២៨-២៩។

អៀង សារី, ខៀវ សំផន, កែ ពក, អៀង ធីរិទ្ធ, វ៉ាន់ រិទ្ធ និង អ៊ុង ជឿន ហៅ តា ម៉ុក។ ចំណែកឯ "**អ្នកទទួលខុសត្រូវខ្ពស់បំផុត**" គឺសំដៅតែ កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលជាប្រធានមន្ទីរសន្តិសុខ ស-២១ តែម្នាក់គត់ ដោយសារ ឌុច បានដើរតួនាទីសំខាន់ក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ មានស្វ័យភាពក្នុងការងារ និងមានអំណាចអនុវត្តជាក់ស្តែងផងដែរ។ ការកំណត់ចំនួនជនដែលត្រូវនាំយកមកកាត់ទោសដ៏តិចតួចនេះ ត្រូវបានលើកឡើងជាហូរហែរ និងមានការជជែកវែកញែកគ្នាយ៉ាងតឹងតែង នាពេលប្រជុំរដ្ឋសភាដើម្បីពិភាក្សា និងអនុម័តលើសេចក្តីព្រាងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលក្នុងនោះបានបង្ហាញថាបុគ្គលដែលនឹងត្រូវស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក គឺមានតិចតួច មិនទូលំទូលាយទេ។

92. ដូច្នេះហើយ ក្នុងខែមីនា ឆ្នាំ១៩៩៩ អំឡុងពេលចរចាបង្កើតច្បាប់ អ.វ.ត.ក អ៊ុង ជឿន ហៅ តា ម៉ុក និង កាំង ហ្កេកអ៊ាវ ហៅ ឌុច ត្រូវបានចាប់ខ្លួន និងឃុំខ្លួនបណ្តោះអាសន្ននៅតុលាការយោធា ក្រោមការចោទប្រកាន់ពីបទ៖ ឧក្រិដ្ឋកម្មសង្គ្រាម ការបំពានលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងឧក្រិដ្ឋកម្មប្រឆាំងទៅលើអ្នកដែលទទួលបានការការពារជាអន្តរជាតិ ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៦ និង ៨ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឆ្នាំ២00១។

93. អ៊ុង ជឿន ហៅ តា ម៉ុក បានស្លាប់នៅខែកក្កដា ឆ្នាំ២00៦។ នៅថ្ងៃទី៣0 ខែកក្កដា ឆ្នាំ២00៧ កាំង ហ្កេកអ៊ាវ ហៅ ឌុច ត្រូវបាននាំខ្លួនពីតុលាការយោធាក្រុងភ្នំពេញ មកឃុំខ្លួននៅ អ.វ.ត.ក ដោយដីការបស់សហចៅក្រមស៊ើបអង្កេតនៃ អ.វ.ត.ក[71]។

94. តាមរយៈបុព្វកថានៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដែលបានអនុមតក្នុងសេចក្តីសម្រេចចិត្តលេខ៖៥៧/២២៨ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២00២ របស់មហាសន្និបាតអង្គការសហប្រជាជាតិ ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ អង្គការសហប្រជាជាតិបានទទួលស្គាល់យ៉ាងជាក់លាក់អំពីការព្រួយបារម្ភពេញច្បាប់របស់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ក្នុងការស្វែងរកយុត្តិធម៌ ការបង្រួបបង្រួមជាតិ ស្ថេរភាព សន្តិភាព និងសន្តិសុខ មានន័យថា ត្រូវថ្លឹងថ្លែងរវាង "យុត្តិធម៌" និង "ការផ្សះផ្សាជាតិ"។

95. ផ្តើមចេញពីការទទួលស្គាល់នេះ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា បានសំដៅតែទៅលើបុគ្គលតែពីរប្រភេទប៉ុណ្ណោះមក

[71] ឯកសារ C4/2 ដីកាបង្គាប់ឲ្យឃុំខ្លួន កាំង ហ្កេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២00៧។

ធ្វើការវិនិច្ឆ័យសេចក្តីគឺ **មេដឹកនាំជាន់ខ្ពស់**កម្ពុជាប្រជាធិបតេយ្យ និង**ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត** ចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។

96. ការពង្រីកវិសាលភាពពាក់ព័ន្ធនឹងយុត្តាធិការបុគ្គល អោ អាន លើសពីវិសាលភាពនៃសំណុំរឿងលេខ ០០១ និង០០២ ដែលកំពុងមានស្រាប់នាពេលបច្ចុប្បន្ន នឹងអូសបន្លាយពេលវេលា និងចំណាយថវិកាដោយមិនចាំបាច់។ ម្យ៉ាងទៀត ពាក់ព័ន្ធនឹងចំនួនជនរងគ្រោះដែលបានបាត់បង់ជីវិតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ការឈឺចាប់របស់ជនរងគ្រោះដែលនៅរស់រានមានជីវិត និងយុត្តិធម៌សម្រាប់ជនរងគ្រោះ អាចទទួលយកបានហើយ និងត្រូវគ្របដណ្តប់ដោយការជំនុំជម្រះសំណុំរឿងលេខ ០០១ និង០០២។

97. សរុបមក សហព្រះរាជអាជ្ញាជាតិ នៅតែចាត់ទុកថា អោ អាន មិនស្ថិតក្នុងយុត្តាធិការបុគ្គលនៃ អ.វ.ត.ក ដូចបានកំណត់ក្នុងមាត្រា ១ នៃច្បាប់ អ.វ.ត.ក ឡើយ។

## IV. ដំណោះស្រាយដែលស្នើសុំ

98. អាស្រ័យដូចបានជម្រាបជូនខាងលើ សហព្រះរាជអាជ្ញាជាតិ សូមស្នើអោយ អង្គបុរេជំនុំជម្រះសម្រេចលើកលែងការចោទប្រកាន់ **អោ អាន** ដោយហេតុថា អ.វ.ត.ក មិនមានយុត្តាធិការបុគ្គលលើ **អោ អាន** ឡើយ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញាជាតិ | ភ្នំពេញ | [signature] |